ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តស្ទឹងត្រែង

លេខ...០៣៣....សភ/សសរ.

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការដោះស្រាយផលប៉ះពាល់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង

## អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៥៣ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ចនិងទំនាក់ទំនងការងារក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងស្មារតីនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២
- យោងសេចក្តីសម្រេចលេខ ០៧៤ សសរ.សលខ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការបែងចែកតួនាទីភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្តស្ទឹងត្រែង ដែលទទួលបានការឯកភាពពីក្រសួងមហាផ្ទៃ លេខ ១២៣១ សរសណ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្តស្ទឹងត្រែង

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតគណៈកម្មការដោះស្រាយផលប៉ះពាល់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ភុល សំអុល** | អភិបាលនៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | លោក **ម៉ៅ ធនិន** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. | លោកស្រី **គង់ ស៊ីផា** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៤. | លោក **យូ ប៉ាសិទ្ធិ** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៥. | លោក **ឈាង ឡាក់** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៦. | លោក **ខៀម ណារ៉េត** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៧. | លោកឧត្តមសេនីយ៍ត្រី **ម៉ៅ សារា** | ស្នងការនគរបាលខេត្ត | សមាជិក |
| ៨. | លោកវរៈសេនីយ៍ឯក **អៀង វ៉ាន់ឌី** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៩. | លោក **ដួង ពៅ** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |



ការិយាល័យ: ភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង
ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
ទូរស័ព្ទ : 074 21 04 07
ទូរសារ : 074 21 04 07 / 074 210 410
អ៊ីមែល : stungtrenghall@stg.ncdd.gov.kh

១០. លោក សន នូ ប្រធានក្រុមប្រឹក្សាស្រុកសេសាន សមាជិក
១១. លោក ពន្លឺ មង្គល អភិបាលនៃគណៈអភិបាលស្រុកសេសាន សមាជិក
១២. លោក ជួរ ជិនសុធា ប្រធានមន្ទីរ ដ.ន.ស.ស ខេត្ត សមាជិក
១៣. លោក ទូច ធា ប្រធានមន្ទីរកសិកម្មខេត្ត សមាជិក
១៤. លោក អេង គិរុង ប្រធានមន្ទីរបរិស្ថានខេត្ត សមាជិក
១៥. លោក សរ គីមណាត ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត សមាជិក
១៦. លោក ខេង ឧិត្យសីហា ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត សមាជិក
១៧. លោក អ៊ុក ធាវី ប្រធានមន្ទីរព័ត៌មានខេត្ត សមាជិក
១៨. លោក ស៊ា គីមសែ ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត សមាជិក
១៩. លោក សៀ ហេង ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត សមាជិក
២០. លោក ហ៊ាង ម៉ូលី ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្ត សមាជិក
២១. លោក នូ សុវណ្ណតារា ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត សមាជិក
២២. លោក ប៉ាង ម៉េង ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត សមាជិក
២៣. លោក ឈាង តុលា នាយខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង សមាជិក
២៤. លោក ឆន ឧុទ្ធី អនុប្រធានមន្ទីរសុខាភិបាលខេត្ត សមាជិក
២៥. លោក ឯក សំឡុ នាយករងទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត សមាជិក
២៦. លោក កៅ វ៉ាងអ៊ីវ តំណាង*ក្រុមហ៊ុន* Hydro Power Lower Sesan 2 សមាជិក។

Draft

**ប្រការ ២.**

គណៈកម្មការដោះស្រាយផលប៉ះពាល់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង និងក្រុមការងារមួយចំនួនជាជំនួយការ ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព កំណត់កាលបរិច្ឆេទសម្រាប់ចុះប្រមូលទិន្នន័យដី ដែលមានផលប៉ះពាល់នៅតាមតំបន់គោលដៅ និងកំណត់ទីតាំងសំរាប់ការតាំងទីលំនៅថ្មី
- ដឹកនាំ សម្របសម្រួលជាមួយអាជ្ញាធរ ក្រុមការងារ ដែលពាក់ព័ន្ធនឹងក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម ២ ដើម្បីចុះពិនិត្យវាស់វែងដីសម្រាប់ធ្វើការដោះស្រាយជូនប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីគម្រោងនេះ
- តាមដាន និងមានផែនការទប់ស្កាត់នូវបាតុភាពនានា ក្នុងដំណើរការដោះស្រាយផលប៉ះពាល់
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ និងបញ្ហាប្រឈមនានា ដើម្បីសុំយោបល់សម្រេចពីប្រធានគណៈកម្មការ
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៣.**

ត្រូវបានបង្កើតក្រុមការងារចុះផ្សព្វផ្សាយគោលនយោបាយសំណងដែលមានសមាសភាពដូចខាងក្រោម៖

១. លោក ឈាង ឡាក់ អភិបាលរង នៃគណៈអភិបាលខេត្ត ប្រធាន
២. លោក ពន្លឺ មង្គល អភិបាល នៃគណៈអភិបាលស្រុកសេសាន អនុប្រធាន
៣. លោក នង សារ៉េត អនុប្រធាននាយកដ្ឋានវារីអគ្គិសនី នៃក្រសួងរ៉ែ និងថាមពល អនុប្រធាន
៤. លោក នូ សុវណ្ណតារា ប្រធានមន្ទីរ រ៉ែ និងថាមពលខេត្ត សមាជិក
៥. លោក សូរ សាំង នាយករងទីចាត់ការរដ្ឋបាលសាលាខេត្ត សមាជិក
៦. លោក យា ច័ន្ទសារ៉ាវុឌ្ឍ មន្ត្រី នៃក្រសួងរ៉ែ និងថាមពល សមាជិក
៧. លោក កៅ វ៉ាងអ៊ីវ តំណាង*ក្រុមហ៊ុន* Hydro Power Lower Sesan 2 សមាជិក
៨. លោក គ្រួ យូ មេភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន សមាជិក
៩. លោក ហ៊ីន លេខ មេភូមិស្រែស្រណុក ឃុំក្បាលរមាស ស្រុកសេសាន សមាជិក
១០. លោក អឿ ធឿន មេភូមិច្រប់ ឃុំក្បាលរមាស ស្រុកសេសាន សមាជិក
១១. លោក លៀង សារឿន មេភូមិស្រែគរ១ ឃុំស្រែគរ ស្រុកសេសាន សមាជិក
១២. លោក ទៃ សៃ មេភូមិស្រែគរ២ ឃុំស្រែគរ ស្រុកសេសាន សមាជិក



អាសយដ្ឋានៈ ភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង
ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
ទូរស័ព្ទ : 074 21 04 07
ទូរសារ : 074 21 04 07 / 074 210 410
អ៊ីមែល : stungtrenghall@stg.ncdd.gov.kh

**ប្រការ ៤.**

ក្រុមការងារចុះផ្សព្វផ្សាយគោលនយោបាយសំណង មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ចុះពន្យល់ ផ្សព្វផ្សាយ និងចែកឯកសារអំពីគោលនយោបាយសំណង ដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ រួមមានឃុំក្បាលរមាស និងឃុំស្រែគរ
- ធ្វើរបាយការណ៍ជូនគណៈកម្មការខេត្តជាប្រចាំអំពីលទ្ធផលនៃការអនុវត្តការងាររបស់ខ្លួន។

**ប្រការ ៥.**

ត្រូវបានបង្កើតក្រុមការងារចុះស្រង់ស្ថិតិ ពិនិត្យ និងកំណត់ទីតាំងឃុំក្បាលរមាស ដែលមានសមាសសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១. | លោក | ម៉ៅ ធនិន | អភិបាលរង នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | លោក | ដួរ ជិនសុធា | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៣. | លោក | សៀ ហេង | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ៤. | លោក | នូ សុវណ្ណតារា | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត | សមាជិក |
| ៥. | លោក | ជាម យូដុង | នាយរងខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែងខេត្ត | សមាជិក |
| ៦. | លោក | គង់ សុធា | អនុប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត | សមាជិក |
| ៧. | លោក | ហាក់ វិមាន | អនុប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ៨. | លោក | ពុយ ចាន់ដារ៉ា | អនុប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត | សមាជិក |
| ៩. | លោក | សាម មនីរឡ្យី | អនុប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |
| ១០. | លោក | សុវណ្ណ ពិសេដ្ឋ | អភិបាលរង នៃគណៈអភិបាលស្រុកសេសាន | សមាជិក |
| ១១. | លោក | អន សំអាត | អធិការនគរបាលស្រុកសេសាន | សមាជិក |
| ១២. | លោក | ឡឿន សម្បត្តិ | មេឃុំក្បាលរមាស | សមាជិក |
| ១៣. | លោក | ឡុត ម៉ារេន | នាយប៉ុស្តិ៍រដ្ឋបាលឃុំក្បាលរមាស | សមាជិក |
| ១៤. | លោក | ហ៊ាន វាសនា | អនុប្រធានការិយាល័យ នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៥. | លោកស្រី | ម៉ិល សោភ័ណនារី | មន្ត្រីទីចាត់ការអន្តរវិស័យ | សមាជិក |
| ១៦. | លោក | ម៉ិន វិចិត្រ | អនុប្រធានការិយាល័យ នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៧. | លោក | កៅ វ៉ាងអ៊ីវ | តំណាងក្រុមហ៊ុន Hydro Power Lower Sesan 2 | សមាជិក |
| ១៨. | លោក | នួន វ៉េត | តំណាងក្រុមហ៊ុន Hydro Power Lower Sesan 2 | សមាជិក |
| ១៩. | លោក | ត្រូ យូ | មេភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន | សមាជិក |
| ២០. | លោក | ហ៊ីន លេខ | មេភូមិស្រែស្រណុក ឃុំក្បាលរមាស ស្រុកសេសាន | សមាជិក |
| ២១. | លោក | អឿ មឿន | មេភូមិច្រប់ ឃុំក្បាលរមាស ស្រុកសេសាន | សមាជិក |
| ២២. | លោក | ហុក ផល្លា | ប្រធានការិយាល័យ ដ.ន.ដ.ភ ស្រុកសៀមប៉ាង | សមាជិក |
| ២៣. | លោក | ពេជ្រ ច័ន្ទបូរ៉ា | អនុប្រធានការិយាល័យ ដ.ន.ដ.ភ ក្រុងស្ទឹងត្រែង | សមាជិក |
| ២៤. | លោក | ស៊ាង សុភ័ក្ត្រ | មន្ត្រី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត | សមាជិក |
| ២៥. | លោក | ណា ដេឡា | មន្ត្រី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត | សមាជិក |
| ២៦. | លោក | លឿង វិសាស័ក្តិ | មន្ត្រី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត | សមាជិក |

**ប្រការ ៦.**

ត្រូវបានបង្កើតក្រុមការងារចុះស្រង់ស្ថិតិ ពិនិត្យ និងកំណត់ទីតាំងឃុំស្រែគរ ដែលមានសមាសសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១. | លោក | យូ ប៉ាសិទ្ធិ | អភិបាលរង នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | លោក | លី ឧសភា | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៣. | លោក | អេង គីរុង | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ៤. | លោក | ប៉ាង ប៉េង | ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត | សមាជិក |
| ៥. | លោក | ទូច ធា | ប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |



អាសយដ្ឋានៈ ភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង
ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
ទូរស័ព្ទ : 074 21 04 07
ទូរសារ : 074 21 04 07 / 074 210 410
អ៊ីមែល : stungtrenghall@stg.ncdd.gov.kh

៦. លោក នូ សុវណ្ណតារា ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត សមាជិក
៧. លោក ឈាង គុលា នាយខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែងខេត្ត សមាជិក
៨. លោក សរ គឹមណារាត ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត សមាជិក
៩. លោក សម្បត្តិ មុន្នី អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត សមាជិក
១០. លោកស្រីឃឿង ស្រីតារី អភិបាលរង នៃគណៈអភិបាលស្រុកសេសាន សមាជិក
១១. លោក ផែន សំអាត អធិការរងនគរបាលស្រុកសេសាន់ សមាជិក
១២. លោក សៀក មេគង្គ មេឃុំស្រែគរ សមាជិក
១៣. លោក ហុត សត នាយប៉ុស្តិ៍រដ្ឋបាលឃុំស្រែគរ សមាជិក
១៤. លោក ថង ស៊ីវាំង នាយប៉ុស្តិ៍រដ្ឋបាលឃុំភ្លុក សមាជិក
១៥. លោក សុន ដាវីន អនុប្រធានការិយាល័យ នៃក្រសួងរ៉ែ និងថាមពល សមាជិក
១៦. លោក គីមញ៉ាន ច័ន្ទអមរិទ្ធ អនុប្រធានការិយាល័យ នៃក្រសួងរ៉ែ និងថាមពល សមាជិក
១៧. លោក កៅ វ៉ាងអ៊ុង តំណាងក្រុមហ៊ុន Hydro Power Lower Sesan 2 សមាជិក
១៨. លោក ម៉ៅ លីណា តំណាងក្រុមហ៊ុន Hydro Power Lower Sesan 2 សមាជិក
១៩. លោក លៀង សារឿន មេភូមិស្រែគរ១ ឃុំស្រែគរ ស្រុកសេសាន សមាជិក
២០. លោក ថៃ សៃ មេភូមិស្រែគរ២ ឃុំស្រែគរ ស្រុកសេសាន សមាជិក
២១. លោក រស់ គីរ៉ា មន្ត្រី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត សមាជិក
២២. លោក សំរិទ្ធ តារ៉ា មន្ត្រី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត សមាជិក
២៣. លោក អ៊ែល មុរ៉ា មន្ត្រី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត សមាជិក
២៤. លោក គេង ពន្លឺ មន្ត្រី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត សមាជិក
២៥. លោក ជា ស៊ីដា មន្ត្រី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត សមាជិក

**ប្រការ ៧.**

ក្រុមការងារចុះស្រង់ស្ថិតិ ពិនិត្យ និងកំណត់ទីតាំងឃុំក្បាលរមាស និងឃុំស្រែគរ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ចុះស្រង់ស្ថិតិប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង
- ចុះពិនិត្យទីតាំងតាមចំណុច និងគូរផែនទីកំណត់សម្គាល់តំបន់ដោយប្រើឧបករណ៍ GPS
- ចុះធ្វើបញ្ជីសារពើភ័ណ្ឌនៃគ្រួសារប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង
- ចុះធ្វើប័ណ្ណ បញ្ជាក់ពីសារពើដី ដែលរងផលប៉ះពាល់ពីគម្រោង
- ចុះធ្វើប័ណ្ណចុះឈ្មោះជ្រើសរើសប្រភេទការតាំងទីលំនៅថ្មី និងការតាំងទីបង្កបង្កើនផល
- ចុះវាស់វែងដី និងលំនៅដ្ឋាន ដែលត្រូវចែកជូនប្រជាពលរដ្ឋ
- ចុះធ្វើប័ណ្ណរៀបចំផ្ទះ ដី
- ចុះធ្វើប័ណ្ណប្រគល់ផ្ទះ ដី
- ចុះធ្វើប័ណ្ណផ្ទេរប្រគល់ព្រំប្រទល់រំដោះដី
- ចុះធ្វើប័ណ្ណចាប់ឆ្នោតជ្រើសរើសយកទីតាំងផ្ទះ និងដីបង្កបង្កើនផល
- ចុះធ្វើប័ណ្ណទូទាត់ប្រាក់
- ធ្វើរបាយការណ៍ជូនគណៈកម្មការថ្នាក់ខេត្ត ជាប្រចាំអំពីលទ្ធផលនៃការអនុវត្តការងាររបស់ខ្លួន
- បំពេញកិច្ចការផ្សេងៗទៀត តាមការណែនាំ និងការប្រគល់ភារកិច្ចរបស់គណៈកម្មការ។

**ប្រការ ៨.**

ត្រូវបានបង្កើតលេខាធិការដ្ឋាន ដែលមានសមាសសភាពដូចខាងក្រោម ៖

១. លោក យូ ប៉ាសិទ្ធិ អភិបាលរងនៃគណៈអភិបាខេត្ត ប្រធាន
២. តំណាងក្រសួងរ៉ែ និងថាមពល អនុប្រធាន
៣. លោក ដួង ពៅ នាយករដ្ឋបាលសាលាខេត្ត អនុប្រធាន



អាសយដ្ឋាន: ភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង
ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
ទូរស័ព្ទ : 074 21 04 07
ទូរសារ : 074 21 04 07 / 074 210 410
អ៊ីមែល : stungtrenghall@stg.ncdd.gov.kh

Draft

| | | | | |
|---|---|---|---|---|
| ៤. លោក | ជួរ | ជិនសុធា | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. លោក | លី | ឧសភា | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | សមាជិក |
| ៦. លោក | ពក | ចាន់ទ្រី | នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៧. លោក | អ៊ួម | សុផល | នាយកស្តីទីទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ៨. លោក | ឯក | សំឡូ | នាយករងទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | សមាជិក |
| ៩. លោក | ឃួន | កញ្ញារ៉ា | អនុប្រធានការិយាល័យសរុប និងព័ត៌មានសាលាខេត្ត | សមាជិក |
| ១០. លោក | ធីក | សុមិន | មន្ត្រីសាលាខេត្ត | សមាជិក |
| ១១. លោកស្រី | ឌី | សុជាតិ | មន្ត្រីសាលាខេត្ត | សមាជិក |
| ១២. លោក | គីន | សុគន្ធ | មន្ត្រីសាលាខេត្ត | សមាជិក |
| ១៣. តំណាងក្រុមហ៊ុន Hydro Power Lower Sesan 2 Co., Ltd | | | | សមាជិក |

**ប្រការ ៩.**

លេខាធិការដ្ឋានមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើការតាមដាន ប្រមូល និងសរុបរបាយការណ៍ ក្រុមការងារនីមួយៗ ជូនប្រធានគណៈកម្មការពិនិត្យ និងផ្តល់យោបល់
- ធ្វើការទំនាក់ទំនងជាប្រចាំ ជាមួយក្រសួងរ៉ែ និងថាមពល និងក្រុមហ៊ុន Hydro Power Lower Sesan 2
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុ ជូនគណៈកម្មការ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំ និងការប្រគល់ភារកិច្ចរបស់ប្រធានគណៈកម្មការ។

**ប្រការ ១០.**

សមាជិកគណៈកម្មការ និងក្រុមការងារនីមួយៗ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទ ដើម្បីជាជំនួយការ ។

**ប្រការ ១១.**

សេចក្តីសម្រេចលេខ ១៥៦ សត.សសរ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១២.**

នាយករដ្ឋបាលសាលាខេត្ត លោកស្នងការនគរបាលខេត្ត លោកមេបញ្ជាការកងរាជអាវុធហត្ថខេត្ត លោកប្រធានក្រុមប្រឹក្សានិងលោកអភិបាលស្រុកសេសាន លោកប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធ លោកមេឃុំ មេប៉ុស្តិ៍រដ្ឋបាល មេភូមិពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ប្រការ៣ ប្រការ៥ ប្រការ៦ និងប្រការ៨ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ស្ទឹងត្រែង, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០១៤

**អភិបាល នៃគណៈអភិបាលខេត្ត**

កុល សំអុល

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងរ៉ែ និងថាមពល
- ប្រធានក្រុមប្រឹក្សាខេត្ត
  *"ដើម្បីគោរពជូនជ្រាប"*
- *ក្រុមហ៊ុន* Hydro Power Lower Sesan 2
  *"ដើម្បីសហការ"*
- ដូចប្រការ១៤
- ឯកសារ-កាលប្បវត្តិ



*ទីតាំងស្នាក់ការ: ភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង*

*ទូរស័ព្ទ : 074 21 04 07*
*ទូរសារ : 074 21 04 07 / 074 210 410*
*អ៊ីមែល : stungtrenghall@stg.ncdd.gov.kn*

Draft




រូបភាពទី ២៤: ផែនទីប្រភេទព្រៃនៅក្នុងតំបន់គំរោង




**រូបភាពទី ២៥: ផែនទីសំណាកព្រៃធ្វើអង្កេត**

ទំរង់បែបបទសំរាប់ការអង្កេត/រាប់មានបង្ហាញដូចខាងក្រោម ហើយលទ្ធផលនៃការរាប់នៅតាមព្រៃមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ៣។

Sample No.:.....................

ឈ្មោះគំរោង: *សិក្សាលទ្ធភាពគំរោងវារីអគ្គិសនីសេសានក្រោមទី២ ក្នុងប្រទេសកម្ពុជា*

Project Name: *Feasibility Study for Lower SESAN 2 Hydropower Project*

**ការសិក្សាអំពីព្រៃឈើ** Forest study

**ប្រភេទព្រៃឈើ** Type of Forest:......................................................

GPS: X:........................ ទំហំផ្ទៃដីដែលសិក្សា Sample size: ......m x.......m = ................m²

Y:........................ រូបថត Photo:.........................កាលបរិច្ឆេទ Date :...........................

| លរ No. | ឈ្មោះឈើ Name of tree | មុខកាត់ឈើ Diameter | | | | | | | | សរុប Total |
|---|---|---|---|---|---|---|---|---|---|---|
| | | 50-100 mm | 200 mm | 300 mm | 400 mm | 500 mm | 600 mm | 700 mm | ......... | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | សរុប Total : | | | | | | | | | |

Draft

រូបភាពទី ២៦ បង្ហាញពីដង់ស៊ីតេរាយៗនៃដើមឈើពេញវ័យ (បរិមាត្ររង្វង់ដែលវាស់គឺធំជាង ៤០ សម ឬ Diameter at Breast Height (DBH) ធំជាង ១២.៧ សម) ដែលមាននៅក្នុងព្រៃស្ងួតរដូវប្រាំង។ យោងតាមការអង្កេតនៅទីវាលកាលពីខែមេសា ឆ្នាំ ២០០៨ នៅក្នុងដង់ស៊ីតេឈើនេះ បានផ្តល់កន្លែងទំនេរច្រើន និង ដីខាងក្រោមគ្របដណ្តប់ដោយឬស្សីខ្លីៗ និង បន្លែផ្សេងៗសំរាប់ចំណីសត្វ ហើយវាក៏សមស្របសំរាប់ពួកមំសាសីសត្វ ដើម្បីប្រមាញ់ចំណីរបស់វាផងដែរ។ វាក៏បានផ្តល់ការរស់នៅសមស្របសំរាប់សត្វ ដើម្បីភៀសខ្លួន និង សំរាប់ជាជំរករបស់វាផងដែរ។




**រូបភាពទី ២៦:** ដង់ស៊ីតេដើមឈើនៅក្នុងព្រៃស្លួតរដូវប្រាំង (deciduous dipterocarp)

Draft

### ៤.២.៤.១ ប្រភេទព្រៃសំខាន់ៗ

ជាទូទៅប្រភេទព្រៃសំខាន់ៗនៅប៉ែកឦសាន និង ប៉ែកខាងកើតនៃប្រទេសកម្ពុជាត្រូវបានចាត់ថ្នាក់ជាព្រៃស្លួតរដូវប្រាំង (DDF) ប៉ុន្តែក៏រួមបញ្ចូលទាំងប្រភេទជំរកដទៃទៀតដូចជា ព្រៃស្លួតរដូវប្រាំងចំរុះ (MDF) និង ព្រៃពាក់កណ្តាលស្រោង (SEF) និង ព្រៃស្រោង (EF) ផងដែរ។ ប្រភេទរុក្ខជាតិដែលមាននៅក្នុងព្រៃប្រភេទនេះ មិនសូវមាននានាភាពដូចនៅក្នុងព្រៃប្រភេទដទៃទៀតទេ ឧទាហរណ៍ ព្រៃស្រោងចំរុះ និង ព្រៃស្រោងជាដើម។ ប៉ុន្តែព្រៃ ប្រភេទនេះទ្រទ្រង់នូវប្រភេទសត្វព្រៃធំៗ និង ចំណីរបស់វាពីព្រោះវាគ្របដណ្តប់នូវទំហំដីធំមួយ នៅប៉ែកឦសាន និង ប៉ែកខាងកើតនៃប្រទេស ដែលមានដង់ស៊ីតេប្រជាជនទាប។

ពូជឈើធម្មតាដែលប្រទះឃើញនៅក្នុងតំបន់គំរោងមានរាយបញ្ជីនៅក្នុងតារាងទី ២៩។ ឈ្មោះពូជឈើទាំងអស់មានពណ៌នានៅក្នុងឧបសម្ព័ន្ធទី ២។

**តារាងទី ២៩:** ពូជឈើឃើញមានជាទូទៅនៅក្នុងតំបន់គំរោង

| No. | ឈ្មោះក្នុងស្រុក | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះគ្រួសារ | ឈ្មោះពូជ |
|---|---|---|---|---|
| ១ | ពពេល | Chan Plu, Merawan | DIPTERACAPRACEAE | HOPEA RECOPEI/ SHOPREA |
| ២ | ពង្រ | | SAPINDACEAE | SCHLEICHER OLEOSA |
| ៣ | ចំបក់ | | IRVINGIACEAE | IRVINGIA MALAYANA |
| ៤ | ចង្រ្កំ | | MIMOSACEAE | XYLIA DOLABRIFORMIS |
| ៥ | ល្បៀង | | HYPERICACEAE | CARTOXYLON ORUNIFOLIUM |
| ៦ | ផ្ចៃផ្លូវ | | | |

| | | | | |
|---|---|---|---|---|
| ៧ | ស្រែងពយ | | CAESALPINIACEAE | BAUHINIA BASSACENSIS |
| ៨ | ធ្នង | | GUTTIFERES | CALLOPHYLLUM SP |
| ៩ | ធ្នង់ | PADAUK | PAPILIONACEAE | PTEROCARPUS PEDATUS |
| ១០ | រការ | | BOMBACACEAE | BOMBAX SP |
| ១១ | ស្រឡៅ | | LYTHRACEAE | LAGERSTROEMIA SPP |
| ១២ | ស្មាក្របី | | MYRISTICACEAE | KNEMA CORTICOSA |
| ១៣ | សង្កែ | | COMBRITACEAE | COMBRITUM QUARANGULARE |

លទ្ធផលនៃការរាប់ព្រៃនៅកំឡុងពេលសិក្សា EIA (កុម្ភៈ-ឧសភា ២០០៨) មានបង្ហាញនៅក្នុងតារាងទី ៣០ ។

**តារាងទី ៣០:** ព្រៃដែលបានរាប់នៅក្នុងតំបន់គំរោង

Draft

| ព្រៃពាក់កណ្តាលស្រោង | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| លេខ សំណាក | ផ្ទៃក្រឡា | ចំនួនដើមឈើដែលមានអង្កត់ផ្ចិតខុសៗគ្នា | | | | | | | សរុប |
| | ម$^{២}$ | ៥០-១០០ មម | ២០០ មម | ៣០០ មម | ៤០០ មម | ៥០០ មម | ៦០០ មម | ៧០០ មម | ... ... | |
| FS-៣ | ១០០០ | ១ | ៧ | ១៩ | ៧ | ០ | | | | ៣៤ |
| FS-៤ | ១០០០ | ២៩ | ១២ | ៩ | ៩ | ៣ | ២ | | | ៦៤ |
| FS-១១ | ២៥០០ | ១៣ | ១២ | ១៣ | ១០ | ១ | | | | ៤៩ |
| FS-១២ | ២៥០០ | ១២ | ១៥ | ១៧ | ១១ | ៧ | ១ | | | ៦៣ |
| FS-១៣ | ២៥០០ | ៦៣ | ៤២ | ១៩ | ១៣ | ២ | ២ | | | ១៤១ |
| FS-១៤ | ២៥០០ | ២១ | ១១ | ២៦ | ១៩ | ៨ | ២ | ១ | | ៨៨ |
| សរុប | ១២០០០ | ១៣៩ | ៩៩ | ១០៣ | ៦៩ | ២១ | ៧ | ១ | | ៤៣៩ |
| | *១០០០០* | *១១៦* | *៨៣* | *៨៦* | *៥៨* | *១៨* | *៦* | *១* | | *៣៦៦* |

| ព្រៃស្រោង | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ចំនួន សំណាក | ផ្ទៃក្រឡា | ចំនួនដើមឈើដែលមានអង្កត់ផ្ចិតខុសៗគ្នា | | | | | | | | សរុប |
| | ម$^{២}$ | ៥០-១០០ មម | ២០០ មម | ៣០០ មម | ៤០០ មម | ៥០០ មម | ៦០០ មម | ៧០០ មម | ..... | |
| FS-៩ | ២៥០០ | ១៦ | ១៥ | ១៨ | ២១ | ១៥ | ៦ | ៦ | | ៩៧ |
| FS-១០ | ២៥០០ | ២៣ | ២៤ | ២១ | ១៣ | ៤ | ២ | | | ៨៧ |
| សរុប | ៥០០០ | ៣៩ | ៣៩ | ៣៩ | ៣៤ | ១៩ | ៨ | ៦ | | ១៨៤ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ១០០០០ | ៧៨ | ៧៨ | ៧៨ | ៦៨ | ៣៨ | ១៦ | ១២ | | ៣៦៨ |
| **ព្រៃស្មូតរដូវប្រាំង (Deciduous Forest)** | | | | | | | | | | |
| ចំនួន សំណាក | ផ្ទៃក្រឡា | ចំនួនដើមឈើដែលមានអង្កត់ផ្ចិតខុសៗគ្នា | | | | | | | | សរុប |
| | ម² | ៥០-១០០ មម | ២០០ មម | ៣០០ មម | ៤០០ មម | ៥០០ មម | ៦០០ មម | ៧០០ មម | ..... | |
| FS-៧ | ១០០០ | ១២ | ១០ | ៧ | ៤ | | | | | ៣៣ |
| FS-៥ | ១០០០ | ៥១ | ៩ | ៣ | | | ១ | | | ៦៤ |
| FS-៦ | ១០០០ | ១៧ | ១១ | ៨ | ៨ | ២ | | | | ៤៦ |
| សរុប | ៣០០០ | ៨០ | ៣០ | ១៨ | ១២ | ២ | ១ | | | ១៤៣ |
| | ១០០០០ | ២៦៧ | ១០០ | ៦០ | ៤០ | ៧ | ៣ | | | ៤៧៧ |
| **Woodland Forest** | | | | | | | | | | |
| ចំនួន សំណាក | ផ្ទៃក្រឡា | ចំនួនដើមឈើដែលមានអង្កត់ផ្ចិតខុសៗគ្នា | | | | | | | | សរុប |
| | ម² | ៥០-១០០ មម | ២០០ មម | ៣០០ មម | ៤០០ មម | ៥០០ មម | ៦០០ មម | ៧០០ មម | ..... | |
| FS-១៥ | ២៥០០ | ២៧ | ១៥ | ១៨ | ៨ | ៥ | ៤ | ៥ | | ៨៦ |
| FS-១៦ | ២៥០០ | ២៩ | ២៦ | ២៦ | ១៨ | ៥ | ០ | ២ | | ១០៦ |
| សរុប | ៥០០០ | ៥៦ | ៤៥ | ៤៤ | ២៦ | ១០ | ៤ | ៧ | | ១៩២ |
| | ១០០០០ | ១១២ | ៩០ | ៨៨ | ៥២ | ២០ | ៨ | ១៤ | | ៣៨៤ |
| **Woodland Deciduous** | | | | | | | | | | |
| ចំនួន សំណាក | ផ្ទៃក្រឡា | ចំនួនដើមឈើដែលមានអង្កត់ផ្ចិតខុសៗគ្នា | | | | | | | | សរុប |
| | ម² | ៥០-១០០ មម | ២០០ មម | ៣០០ មម | ៤០០ មម | ៥០០ មម | ៦០០ មម | ៧០០ មម | ..... | |
| FS-១៧ | ២៥០០ | ៨០ | ៣០ | ២០ | ១២ | ៧ | ១ | ២ | | ១៥២ |
| FS-១៨ | ២៥០០ | ៣០ | ៥២ | ៤៩ | ១៦ | ០ | ០ | ០ | | ១៤៧ |
| សរុប | ៥០០០ | ១១០ | ៨២ | ៦៩ | ២៨ | ៧ | ១ | ២ | | ២៩៩ |
| | ១០០០០ | ២២០ | ១៦៤ | ១៣៨ | ៥៦ | ១៤ | ២ | ៤ | | ៥៩៨ |

Draft

ពីការអង្កេតព្រៃឈើបានរកឃើញថា ព្រៃក្នុងតំបន់គំរោងមានការថយចុះបរិមាណ និង គុណភាព ហើយឈើដែលមានអង្កត់ផ្ចិតតូច និង ឈើដែលមានតំលៃនៅមានសេសសល់ ដោយសារសំពាធដែលមិនអាចគ្រប់គ្រងបានពីសកម្មភាពរបស់មនុស្ស ការអភិវឌ្ឍន៍ដី និង កត្តាដទៃទៀត។

អាងដែលបានស្នើឡើងនៅក្នុងរោងចក្រវារីអគ្គិសនីទន្លេសេសានក្រោម ២ នឹងជន់លិចតំបន់ព្រៃជាច្រើនគីឡូម៉ែត្រការ៉េនៅតាមដងទន្លេសេសាន និង ទន្លេស្រែពក។ តំបន់តាំងទីលំនៅដែលបានស្នើ នឹងធ្វើអោយខូចខាតព្រៃឈើរាប់ពាន់ផងដែរ។ រូបភាពទី ២៧ បង្ហាញពីតំបន់ព្រៃឈើដែលនឹងត្រូវជន់លិចនៅក្នុងទីតាំងអាង និង តំបន់ព្រៃដែលនឹងខូចខាតដោយសារការផ្លាស់ទីលំនៅថ្មីសំរាប់ PAH/APs។

ដូចគេគ្រប់គ្នាបានដឹង ព្រៃឈើដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសំអាតបរិយាកាស (ស្រូប $CO_2$ និង ផលិត $O_2$) ជាជំរកសត្វព្រៃ ការពារព្យុះ និង សំណឹក បំរើបំរាស់ក្នុងលំនៅដ្ឋាន និង ឧស្សាហកម្ម និង ប្រើសំរាប់អភិវឌ្ឍន៍អេកូទេសចរណ៍។ គុណតំលៃបរិស្ថានខ្លះអាចធ្វើការគណនាពី Biomass នៃប្រភេទព្រៃនិមួយៗ។ ផ្អែកលើស្ថានភាពបច្ចុប្បន្នរបស់ព្រៃនៅក្នុងតំបន់គំរោងគេអាចកំណត់ Biomass របស់វាដូចខាងក្រោម:

| ប្រភេទព្រៃ | ផ្ទៃក្រឡា (ហត) | ជីវម៉ាសក្នុងមួយតោន DM/ហត** | សរុបជីវម៉ាស តោន |
|---|---|---|---|
| **នៅក្នុងទីតាំងអាងជាមួយ FSL ៧៥ម** | | | |
| មិនមែនព្រៃឈើ | ៥៨៣១.៤៦១០ | 0 | 0 |
| Woodland Evergreen | ៤២.០៧០ | ៧០ | ២.៩៤៤.៩០០ |
| Woodland Deciduous | ៨៣២.៦២៩ | ៨៥ | ៧០.៧៧៣.៤៦៥ |
| ព្រៃស្ងួតរដូវប្រាំង | ២៣.០៩៣.០២៧ | ១២០ | ២.៧៧១.១៦៣.២៤០ |
| ព្រៃពាក់កណ្តាលស្រោង | ៣.៥១៦.៥៤៥ | ២០០ | ៧០៣.៣០៩.០០០ |
| ព្រៃស្រោង | ២៤៨.១៩២ | ៣០០ | ៧៤.៤៥៧.៦០០ |
| **សរុប** | **៣៣.៥៦៣.៩២៤** | | **៣.៦២២.៦៤៨.២០៥** |
| **នៅក្នុងតំបន់តាំងទីលំនៅ** | | | |
| មិនមែនព្រៃឈើ | ៥៨០.៤០៤ | 0 | 0.00 |
| Woodlan Deciduous | ២២៦.៦៥១ | ៨៥ | ១៩.២៦៥.៣៤ |
| Woodlan Evergreen | ១.៤៩៩ | ៧០ | ១០៤.៩៣ |
| ព្រៃស្ងួតរដូវប្រាំង | ៤.៦១៨.៦៧៧ | ១២០ | ៥៥៤.២៤១.២៤ |
| ព្រៃពាក់កណ្តាលស្រោង | ១.៥៥៦.៩១៩ | ២០០ | ៣១១.៣៨៣.៨០ |
| ព្រៃស្រោង | ១០២.៦៥២ | ៣០០ | ៣០.៧៩៥.៦០ |
| **សរុប** | **៧.០៨៦.៨០២** | | **៨៩៦.៥២៥.៩៧០** |

<u>សំគាល់:</u> ** ប្រភព: ការណែនាំ IPCC សំរាប់ការចុះបញ្ជីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ, ១៩៩៦, ទំព័រទី ៥.២៧ និង ៥.២៨

Draft

កន្លែងតាំងទីលំនៅដែលបានស្នើនៅទន្លេសេសានមានទីតាំងស្ថិតនៅផ្នែកខាងជើងនៃទន្លេ ហើយស្ថិតនៅចំងាយប្រហែល ២ ទៅ ៣ គីឡូម៉ែត្រពីច្រាំងទន្លេ។ ទីតាំងនេះ ស្ថិតនៅចន្លោះទន្លេសេសាន និង ទន្លេសេកុង ហើយលាតសន្ធឹងទៅផ្នែកខាងជើង និង ផ្នែកឦសានឆ្ពោះទៅឧទ្យានជាតិវីរជ័យ ស្ថិតនៅក្នុងខេត្តរតនគីរី។ ឧទ្យានជាតិវីរជ័យគ្របដណ្តប់ និង ទ្រទ្រង់ប្រភេទព្រៃមួយចំនួនធំរួមមានព្រៃពាក់កណ្តាលស្រោង និង ព្រៃស្រោង ហើយវាលាតសន្ធឹងទៅផ្នែកឦសានយ៉ាងឆ្ងាយទៅដល់តំបន់ភ្នំអាណ្ណាមីតកណ្តាល នៅក្នុងប្រទេសវៀតណាម។ វាក៏បានភ្ជាប់ទៅនឹងតំបន់ការពារ Xe Pian នៅឡាវភាគខាងជើងផងដែរ។ តំបន់ទាំងមូលអាចចាត់ទុកជាតំបន់ឆ្លងព្រំដែន របស់ប្រទេសឥណ្ឌូចិនផងដែរ។ បន្ថែមលើនេះ ជំរកព្រៃបានទ្រទ្រង់ជីវិតសត្វព្រៃមួយភាគធំ ជាពិសេសប្រភេទថនិក សត្វធំៗដែលមានការគំរាមកំហែងជាសកល[៤] និង ប្រភេទដែលកំពុងមានគ្រោះថ្នាក់ដទៃទៀត ដែលមានតំលៃសំរាប់ការអភិរក្ស។

តំបន់ព្រៃឈើនៃតំបន់តាំងទីលំនៅជាថ្មី ធ្លាប់បានស្ថិតនៅក្រោមប្រតិបត្តិការខ្នាតធំនៃការកាប់ព្រៃសម្បទាន ដូច្នេះធ្វើអោយដើមឈើធំៗដែលមានតំលៃពាណិជ្ជកម្មខ្ពស់ត្រូវបានកាប់ ហើយដែនជំរកសត្វព្រៃត្រូវបានបែកខ្ញែក។ បច្ចុប្បន្ននេះ ព្រៃនៅតំបន់តាំងទីលំនៅជាថ្មីក្នុងស្រុកសេសានត្រូវបានរំខានដោយសារស្នាម/ផ្លូវរថយន្តធំៗ ដែលផ្តល់នូវភាពងាយស្រួលក្នុងការចេញចូលក្នុងតំបន់នេះ។ ផលប៉ះពាល់ជាអវិជ្ជមានរបស់សកម្មភាពមនុស្ស អាចជាសន្ទស្សន៍មួយបញ្ជាក់ពីការរំខានដល់សត្វព្រៃនៅក្នុងតំបន់ ដែលធ្វើស្របគ្នាជាមួយការកាប់ឈើ ដោយមិនបានហាមឃាត់។

នៅក្នុងតំបន់តាំងទីលំនៅជាថ្មីស្រែពក គេបានរកឃើញថាតំបន់ព្រៃទាំងមូល ទាំងក្នុង និង នៅជុំវិញតំបន់តាំងទីលំនៅនោះ ត្រូវបានកំណត់លក្ខណៈជាព្រៃស្ងួតនៅរដូវប្រាំង ហើយប្រភេទដែលដុះនៅខាងក្រោមម្លប់មានលើសលុបដោយគុម្ពោតព្រៃ និង ឫស្សីខ្លីៗ។ ដើមឈើដែលមាននៅក្នុងជំរកនេះមានរាយមួយៗ និង ទំហំតូច ប៉ុន្តែដើមដែលមានទំហំទទឹងធំៗ ត្រូវស្ថិតនៅក្រោមការជ្រើសរើសដើម្បីកាប់ ជាពិសេសប្រភេទដែលមានតំលៃពាណិជ្ជកម្មខ្ពស់ សំរាប់ជាសម្ភារៈសំណង់។ ជាទូទៅនៅក្នុងជំរកព្រៃស្ងួតនៅរដូវប្រាំង បែបនេះ វាមានកំពស់ជាមធ្យមប្រហែលពី ៧.៥ម ទៅលើស ១៨ម នៃឈើដែលមានមែកសាខា។ ដើមឈើដែលដុះឡើងផុតគឺមានកំពស់ជាមធ្យមប្រហែល ២៣ម។

[៤] ពូជដែលត្រូវបានគំរាមកំហែងជាសកលរាប់បញ្ចូលពពួកសត្វធំៗដូចជា ទន្សោង ខ្ទីង ដំរី ក្របីព្រៃ ខ្លា ខ្លាឃ្មុំ រមាំង ក្តាន Sambar ទោចពង្រូល ក្រុមសត្វដែលមានលំដាប់ខ្ពស់ ក៏ដូចជាក្រុមបក្សី ជាឧទាហរណ៍ ពពូ ក្ង ងាវកក អកត្រី ត្មាត ក្រោក និង បក្សីផ្សេងទៀត។ សេចក្តីលំអិតបន្ថែមទៀតមានភ្ជាប់ក្នុងសេចក្តីបន្ថែម។




**រូបភាពទី ២៧: ផែនទីតំបន់ព្រៃឈើនិងរងផលប៉ះពាល់ដោយសារគំរោង**

### ៤.២.៤.២ ផលិតផលព្រៃឈើ និង អនុផលព្រៃឈើ

ការប្រមូលអនុផលព្រៃឈើដូចជា ជ័រឈើ ទឹកឃ្មុំ និងផ្លែឈើព្រៃ នៅក្នុងតំបន់តាំងទីលំនៅមិនបានផលច្រើនទេ ប៉ុន្តែការកាប់ឈើដោយជ្រើសរើសអាចមើលឃើញថាជាសកម្មភាពដែលគ្មានការទប់ស្កាត់មួយ។ សំលេងរណារច្រវ៉ាក់ ដែលកំពុងប្រតិបត្តិការនៅពេលថ្ងៃត្រូវបានឮដោយក្រុមអ្នកសិក្សា។ ជាញឹកញាប់ គេអាចឃើញគំនរឈើដែលលាក់ទុកដោយគ្របស្លឹកឈើនៅក្នុងព្រៃ និង នៅកន្លែងដែលងាយស្រួលដឹកជញ្ជូន។

ក្រុមសិក្សារបស់ KCC បានរកឃើញថា ការប្រមូលអនុផលព្រៃឈើ (NTFPs) ដូចជាជ័រឈើ ផ្លែឈើព្រៃ និង ទឹកឃ្មុំ មិនសូវមានសកម្មភាពទេនៅក្នុងតំបន់គំរោង ប៉ុន្តែមានការកាប់ឈើដោយជ្រើសរើស បើយោងទៅតាមការចុះអង្កេតដល់ទីកន្លែង។ ស្នាម/ផ្លូវរថយន្តមួយចំនួន ផ្តល់ជាច្រកចេញចូលថែមទៀត ទៅក្នុងព្រៃជ្រៅដើម្បីកាប់ឈើ និង បរបាញ់សត្វព្រៃផងដែរ។ សំលេងរណារច្រវ៉ាក់អាចឮឡើងនៅក្នុងព្រៃ ហើយគំនរឈើអាចមើលឃើញនៅពេលក្រុមសិក្សាកំពុងធ្វើការនៅក្នុងតំបន់។ ការកាប់ឈើប្រណិត និង ឈើគុណភាពលេខមួយសំរាប់ប្រើប្រាស់ក្នុងតំបន់ នៅតែមាននៅក្នុងព្រៃទាំងមូល។

ពូជឈើនៅក្នុងគ្រួសារ Dipterocarpaceae ជាពូជដែលមានចំនួនច្រើនជាងគេដែលមាននៅក្នុងព្រៃប្រភេទនេះ។ ព្រៃស្ងួតរដូវប្រាំង មានលក្ខណៈពិសេសដោយមានមែកសាខា និង ដើមនិមួយៗ ឈរដាច់ៗពីគ្នាហើយប្រភេទខ្ពស់ៗ មានដូចជា ឈ្លីក ផ្ចឹក ខ្លុង សុក្រំ ជាដើម ។ នៅខាងក្រោមដើមឈើមានគ្របដណ្តប់ដោយស្មៅគុម្ពោតព្រៃ និង ឫស្សីខ្លីៗ ដែលបាន បង្ហាញពីការអង្កេត និង *(C. Daltry & Frank Momberg, ភ្នំក្រវ៉ាញ, ការអង្កេតជីវសាស្ត្រ ចំរុះ ២០០០)*។

### ៤.២.៥ ពូជកម្រ ឬ ពូជកំពុងរងគ្រោះថ្នាក់

នៅកំឡុងពេលអង្កេតនៅទីវាល យើងមិនបានជួបសត្វគោកដែលជាពូជកម្រ និង កំពុងរងគ្រោះទេ ប៉ុន្តែពតិមានដែលទទួលបានពីអ្នកផ្តល់ពតិមានគន្លឹះនៅក្នុងសហគមន៍នៅស្រែគរ និង តាឡាត់ បានប្រាប់ថាសត្វព្រៃគោកភាគច្រើននៅតែមានបង្ហាញខ្លួននៅក្នុងតំបន់គំរោង ជាពិសេសនៅក្នុងព្រៃក្រាស់ៗ និង ឆ្ងាយពីភូមិរស់នៅ។ តាមការសិក្សាពីត្រីនៅក្នុងទន្លេសេសាន និង ទន្លេស្រែពកពីខែ កុម្ភៈ - ឧសភា ២០០៨ បានរកឃើញពូជត្រីកំរ ដែលមានចុះបញ្ជីនៅក្នុងតារាងទី ១៩ ក្នុងចំនុច ៤.២.១.២។

ជាងនេះទៅទៀត តាមការសិក្សាពីមុនៗ និង កំពុងធ្វើដោយ WWF និង WFF បញ្ជាក់ថា នៅប៉ែកឦសាន និង ប៉ែកខាងកើតនៃប្រទេសកម្ពុជា មានសត្វព្រៃជាច្រើនប្រភេទរួមបញ្ចូលទាំងពូជកំរ និង កំពុងរងគ្រោះផងដែរ។ ក្នុងតារាងទី ៣១ គឺជាបញ្ជីពូជកំរ/ងាយរងគ្រោះ និង កំពុងជួបគ្រោះថ្នាក់ ដែលរាប់បញ្ចូលពូជកំរ នៅក្នុងតំបន់គំរោង ដូចជា ខ្ទីង ទន្សោង ។ល។

**តារាងទី ៣១:** បញ្ជីពូជសត្វកំរ/ងាយរងគ្រោះ និងជួបគ្រោះថ្នាក់នៅប៉ែកឦសាន និង ប៉ែកខាងកើតនៃប្រទេសកម្ពុជា



Draft

| លរ | ឈ្មោះក្នុងតំបន់ | ឈ្មោះភាសា អង់គ្លេស និង ( ឈ្មោះវិទ្យាសាស្ត្រ) | ស្ថានភាព |
|---|---|---|---|
| **A) ថនិកសត្វ** | | | |
| ១ | ដំរី | Asian elephant (*Elephas maximus*) | EN (IUCN) |
| ២ | ខ្លាធំ | Tiger (*Panthera tigris*) | EN (IUCN) |
| ៣ | ខ្លាពពក | Clouded leopard (*Neofelis nebulosa*) | VU (IUCN) |
| ៤ | ខ្លាឃ្មុំធំ | Asiatic black bear (*Ursus thibetanus*) | VU (IUCN) |
| ៥ | ខ្លាលឿងមាស | Asian golden cat (*Catopuma temminckii*) | N-t (IUCN) |
| ៦ | ក្របីព្រៃ | Wild Water Buffalo (*Bubalus arnee*) | EN (IUCN) |
| ៧ | រមាំង | Eld's Deer (*Cervus eldii*) | VU (IUCN) |
| ៨ | ទន្សោង | Banteng (*Bosjavanicus*) | EN (IUCN) |
| ៩ | ស្វាក្រវ៉ាត់ | Douc Langur (*Pygathrix nemaeus*) | EN (IUCN) |
| ១០ | ទោច | Pileated Gibbon (*Hylobates piletus*) | VU (IUCN) |
| ១១ | ទោចថ្ពាល់លឿង | Yellow-cheeked Gibbon (*Hylobates gabriellae*) | VU (IUCN) |
| ១២ | ភេក្បាលសំប៉ែត | Eurasian Otter (*Lutra lutra*) | VU (IUCN) |
| ១៣ | ខ្ទីង | Gaur (*Bos gaurus*) | VU (IUCN) |
| ១៤ | ស្វាអង្កត់ | Stump-tailad Macaque (*Macaca arctoides*) | VU (IUCN) |
| ១៥ | ស្វាព្រាម | Silvered Langur (*Semnopithecus cristatus*) | NT (IUCN) |
| ១៦ | សំពោចកំពឹងដូង | Owston's Civet (*Hemigalus owstoni*) | VU (IUCN) |
| ១៧ | កំប្រុកស្លាបធំ | Particoloured Flying Squirrel (*Hylopetes alboniger*) | EN (IUCN) |
| ១៨ | កំប្រុកធំ | Black Giant Squirrel (*Ratufa bicolor*) | II (CITES) |
| ១៩ | ស្វាគ្រោស | Pig-tailed Macaque (*Macaca nemestrina*) | VU (IUCN) |
| ២០ | ឆ្កែព្រៃ | Dhole (*Cuon alpinus*) | VU (IUCN) |
| ២១ | ប្រម៉ា | East-Asian Porcupine (*Hystrix brachyura*) | VU (IUCN) |
| **B) បក្សី** | | | |
| ១ | ក្រៀល | Sarus Crane (*Grus antigone*) | |
| ២ | ត្រយេក្ស | Giant Ibis (*Pseudibis gigantea*) | |
| ៣ | ត្រចំក្រោមក | White-shouldered Ibis (*Pseudibis davisoni*) | |
| ៤ | ត្រដក់ធំ | Greater Adjutant (*Leptoptilus dubius*) | |

Draft

| | | | |
|---|---|---|---|
| ៥ | ត្រដក់តូច | Lesser Adjutant (*Leptoptilus javanicus*) | |
| ៦ | រនាលស | Milky Stork (*Mycteria cinerea*) | |
| ៧ | អង្គត់ខ្មៅ | Black-necked Stork (*Ephippiorhynchus asiaticus*) | |
| ៨ | ក្រសារ | Wolly-necked Stork (*Ciconia episcopus*) | |
| ៩ | ក្ងោកបៃតង | Green Peafowl (*Pavo muticus*) | VU (IUCN) |
| ១០ | ស្តេចកូលីត | Siamese Fireback (*Lophura diardi*) | NT (IUCN) |
| ១១ | មាន់ទោបៃតងប្រផេះ | Germain's Peacock Pheasant (*Polyplectron germaini*) | VU (IUCN) |
| ១២ | កេងកងតូច | Oriental Pied Hornbill (*Anthracoceros albirostris*) | II (CITES) |
| ១៣ | កេងកងធំ | Great Hornbill (*Buceros biconis*) | NT (IUCN) |
| ១៤ | ប៉ូរង់ | Wreathed Hornbill (*Aceros undulatus*) | II (CITES) |
| ១៥ | រអាតឃ្មុំ | Oriental Honey-buzzard (*Pernis ptilorhyncus*) | II (CITES) |
| ១៦ | ស្ទាំងរលេក | Black-shouldered Kite (*Elanus caeruleus*) | II (CITES) |
| ១៧ | អកក្បាលប្រផេះ | Grey-headed Fish Eagle (*Ichthyophaga ichthyaetus*) | NT (IUCN) |
| ១៨ | អកតូច | Lesser Fish Eagle (*Ichthyophaga humilis*) | NT (IUCN) |
| ១៩ | ត្មាតខ្មៅ | Cinereous Vulture (*Aegypius monachus*) | NT (IUCN) |
| ២០ | អកពស់ព្រៃ | Crested Serpent Eagle (*Spilornis cheela*) | II (CITES) |
| ២១ | រអាតទន្សាយ | Eastern Marsh Harrier (*Circus spilonotus*) | II (CITES) |
| ២២ | ស្ទាំងស្លាបផែក | Shikra (*Accipiter badius*) | II (CITES) |
| ២៣ | ស្ទាំងស្លាបស្រួច | Collared Falconet (*Microhierax caerulescens*) | II (CITES) |
| ២៤ | ស្នាញ | Darter (*Anhinga melanogaster*) | NT (IUCN) |
| ២៥ | កុកគ្រោងធំ | Great Egret (*Casmerodius albus*) | III (CITES) |
| ២៦ | កុកគ្រោង | Intermediate Egret (*Mesophoyx intermedia*) | III (CITES) |
| ២៧ | កុកគូ | Cattle Egret (*Bubulcus ibis*) | III (CITES) |
| **C) ល្មូន** | | | |
| ១ | ក្រពើភ្នំ | Siamese Crocodile (*Crocodylus siamensis*) | CR (IUCN) |
| ២ | អណ្តើកក្បាលធំ | Big-headed Turtle (*Platystemon megacephalum*) | EN (IUCN) |
| ៣ | អណ្តើកបិទមុខ | Indochinese Box Turtle (*Cuora galbinifrons*) | CR (IUCN) |
| ៤ | អណ្តើកព្រេច | Elongated Tortoise (*Indotestudo elongata*) | EN (IUCN) |

Draft

| | | | |
|---|---|---|---|
| ៥ | អណ្តើកបិទមុខស្លឹកខ្មៅ | Asian Box Turtle (*Cuora amboinensis*) | VU (IUCN) |
| ៦ | អណ្តើកសាកល | Malayan Snail-eating Turtle (*Malayemys subtrijuga*) | VU (IUCN) |
| ៧ | អណ្តើកក្អែក | Black Marsh Turtle (*Siebenrockiella crassicollis*) | VU (IUCN) |
| ៨ | អណ្តើកក្របី | Yellow-headed Temple Turtle (*Hieremys annandalii*) | EN (IUCN) |
| ៩ | កន្ធាយអាស៊ី | Asian Softshell Turtle (*Amyda cartilaginea*) | VU (IUCN) |
| ១០ | កន្ធាយក្បាលផែប | Asian Giant Softshell Turtle (*Pelochelys cantorii*) | EN (IUCN) |
| ១១ | ពស់ថ្លាន់តូច | Burmese Python (*Python molurus bivittatus*) | N-t (IUCN) |
| ១២ | អន្សោង | Water Monitor (*Varanus salvator*) | II (CITES) |
| ១៣ | ត្រកួត | Bengal Monitor (*Varanus bengalensis*) | I (CITES) |
| ១៤ | ពស់ថ្លាន់ធំ | Reticulated Python (*Python reticulatus*) | II (CITES) |
| ១៥ | ពស់ព្រៃកណ្តុរ | Common Rat Snake (*Ptyas mucosus*) | II (CITES) |
| ១៦ | ពស់វែករនាម | King Cobra (*Ophiophagus hannah*) | II (CITES) |
| ១៧ | ពស់វែកក្របី | Monocled Cobra (*Naja kaouthia*) | II (CITES) |
| ១៨ | ពស់វែកដំបូក | Indochinese Spitting Cobra (*Naja siamensis*) | II (CITES) |

### ៤.២.៦ តំបន់ការពារ

ឧទ្យានជាតិវីរជ័យ មានទីតាំងនៅប៉ែកឦសាននៃទីតាំងអាង មានចំងាយប្រហែល ១០០គម ខាងលើខ្សែទឹកនៃតំបន់គំរោង។ ឧទ្យានសត្វព្រៃលំផាត់ស្ថិតនៅប៉ែកអគ្នេយ៍នៃតំបន់គំរោង មានចំងាយ ១០គម ពីខ្សែទឹកលើនៃព្រំដែនអាងដែលបានស្នើនៃរោងចក្រវារីអគ្គីសនីសេសានក្រោម២។ ប៉ុន្តែខាងក្នុងអាងដែលបានស្នើ មានសហគមន៍ព្រៃឈើមួយឈ្មោះ "អ្នកតា ការកាន់ " ដែលស្ថិតនៅពីក្រោយភូមិស្រែគរ ១ និង ភូមិស្រែគរ ២។ ផ្ទៃដីសរុបរបស់សហគមន៍ព្រៃឈើនេះមាន ២០០៣ ហត បានទទួលពីប្រធានសហគមន៍ព្រៃឈើ លោក ហ៊ួន ហេង។ រូបភាពទី ២៨ បង្ហាញពីតំបន់ការពារនៅក្នុងប្រទេសកម្ពុជា។

Draft




រូបភាពទី ២៨: ផែនទីនៃតំបន់ការពារ

## ៤.៣ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

### ៤.៣.១ ឧស្សាហកម្ម

សិប្បកម្មប្រហែល ១៩០ កំពុងប្រតិបត្តិការនៅក្នុងខេត្តស្ទឹងត្រែងទាំងមូល ដែលក្នុងនោះមានសិប្បកម្មមួយទទួលបានអជ្ញាប័ណ្ណពី MIME សិប្បកម្ម ៥៩ អនុញ្ញាតិដោយ DIME, និង ១៣០ សិប្បកម្មផ្សេងទៀត ជាប្រតិបត្តិការបែបគ្រួសារដោយគ្មានអជ្ញាប័ណ្ណ។ ការផលិតអាហារ និង គ្រឿងសង្ហារឹម មានច្រើនក្នុងលក្ខណៈជាសិប្បកម្មនៅក្នុងខេត្ត។ គ្មានរោងចក្រ ឬ សកម្មភាពឧស្សាហកម្មចំបងទេ នៅក្នុងខេត្តស្ទឹងត្រែង។

បច្ចុប្បន្ននេះ ការអភិវឌ្ឍន៍រ៉ែ មានសក្តានុពលខ្លាំងជាងគេ សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មនៅក្នុងខេត្ត។ ឧទាហរណ៍ សំភារៈសំណង់តូចៗ ៣ (ថ្មបាយក្រៀម/ដី ខ្សាច់ និង គ្រួស) នៅឃុំព្រះបាត ក្នុងស្រុកស្ទឹងត្រែង និង ក្រុមហ៊ុនរុករកលោហៈ និង រ៉ែត្បូងថ្មដែលមានអជ្ញាប័ណ្ណចំនួន ៥ ក្រុមហ៊ុនទៀតនៅក្នុងទឹកដីស្រុកសេសាន ស្រុកសៀមប៉ាង និង ស្រុកថាឡាបរិវត្តិ។

**តារាងទី ៣២:** ក្រុមហ៊ុនរុករករ៉ែ ៥ ដែលមានអជ្ញាប័ណ្ណក្នុងការអភិវឌ្ឍន៍នៅខេត្តស្ទឹងត្រែង

| លរ | ឈ្មោះក្រុមហ៊ុន | ប្រភេទរ៉ែ | ទីតាំង | ស្ថានភាព |
|---|---|---|---|---|
| ១ | ទ្រី ភាព | ដែក | ស្រុក ថាឡាបរិវត្ត | រុករក |
| ២ | អាន មារឌី | ត្បូងថ្ម | ឃុំតាឡាត់ ស្រុកសេសាន | រុករក |
| ៣ | ឥណ្ឌូចិន រីសសស៍ Ltd. | លោហៈ | កាចុកបឹងងឹងកង និង ពោងពាយ ស្រុកសៀមប៉ាង | រុករក |
| ៤ | កេណីតិច Co.Ltd | លោហៈ | អូរកោងកាង ស្រុក ថាឡាបរិវត្ត | រុករក |
| ៥ | កេណីតិច Co.Ltd | លោហៈ | ភូមិកូនហ៊ី ថាឡាបរិវត្ត ស្ទឹងត្រែង និង ជីបព្រះវិហារ | រុករក |

យោងតាមផែនទីរ៉ែនៃប្រទេសកម្ពុជាក្នុងទសវត្សឆ្នាំ១៩៦០ បង្ហាញថានៅផ្នែកខាងលើនៃទីតាំងអាងនៅក្នុងឃុំតាឡាត់ មានបង្កប់នូវរ៉ែត្បូងថ្ម។ ក្នុងពេលនេះ មានក្រុមហ៊ុនឯកជនមួយកំពុងធ្វើការរុករករ៉ែត្បូងថ្ម នៅផ្នែកខាងលើនៃឃុំតាឡាត់ នៅចន្លោះព្រំដែនខេត្តស្ទឹងត្រែង និង រតនគិរី (នៅក្នុងតំបន់អូរក្រឡា) យោងទៅតាមលោក ហុល ប៊ុណ្ណាត ជំទប់ទីមួយឃុំតាឡាត់។ នៅឆ្នាំ ១៩៦០ កម្មករខ្មែរប្រហែល ១០០ នាក់ ត្រូវបានបញ្ជូនទៅតំបន់នេះដើម្បីរុករកត្បូងថ្ម ហើយនៅឆ្នាំ ១៩៧៦-១៩៧៧ ក្នុងរបបខ្មែរក្រហម ធនធាននេះត្រូវបានទាញយក ១,៥ ឆ្នាំ។

ការងារស៊ើបអង្កេត និង ការវិភាគទិន្នន័យបង្ហាញថា ធនធានរ៉ែនៅក្នុងរង្វង់តំបន់អាងស្តុកទឹករោងចក្រវារីអគ្គិសនីសេសានក្រោម ២ អាចចាត់ទុកបានថា ខ្សត់ខ្សោយ ដែលមានបញ្ជាក់ពីប្រភេទដូចខាងក្រោម:

- ក្រុមលោហៈ មានតែលោហៈចំរុះ និង កន្លែងដែលមានរ៉ែមាស។
- ក្រុមសារធាតុបន្ថែម: ការកើតឡើងនៃដែកថ្មបាយក្រៀម ប្រើសំរាប់បន្ថែមលើស៊ីម៉ង់
- ក្រុមសម្ភារៈសំណង់: មានច្រើនក្រុម រួមបញ្ចូលទាំងស្រទាប់រ៉ែ facing stone ខ្នាតតូច ដីសំរាប់ធ្វើអិដ្ឋ និង ក្បឿង ខ្សាច់ក្វាតគុណភាពខ្ពស់ និង ដុំថ្ម និង គ្រួសសំរាប់បេតុង។

**តារាងទី ៣៣:** ស្រទាប់រ៉ែ/កន្លែងយករ៉ែ ក្នុងតំបន់អាងស្តុកទឹកនិងតំបន់នៅក្បែររោងចក្រវារីអគ្គិសនីសេសានក្រោម ២

| លរ | ប្រភេទនៃធនធានរ៉ែ | ខ្នាត | កូអរដោនេនៃចំនុចកណ្តាល |
|---|---|---|---|
| ១ | ខ្សាច់ គ្រួស | ស្រទាប់រ៉ែខ្នាតតូច | X=៣៥៧០៥៥.៩៤២៣; Y=១៥៣០៩៤៧.៩៣៩៩<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |
| ២ | ខ្សាច់ គ្រួស | ស្រទាប់រ៉ែខ្នាតតូច | X= ៣៥៤៥៩២.០៨៩៦; Y= ១៥២៩០៩៥.៧៤៦៩<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |
| ៣ | ដែកថ្មបាយក្រៀម | ការកើតឡើងសារធាតុរ៉ែ | X=៣៣៣៤៨១.៧៨៩១; Y= ១៥៣០៩៤៧.៩៣៩៩<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |

| | | | |
|---|---|---|---|
| ៤ | ដីធ្វើអិដ្ឋ និង ក្បឿង | ស្រទាប់រ៉ែខ្ពាតតូច | X= ៣៣៨១៨៦.៦៣៥៣; Y=១៥១៣៥៨៣.៧៨១៩<br>កំពស់ដាច់ខាត: >៧៥ម គ្មានជំនន់ |
| ៥ | Polymetallic sulphide | ការកើតឡើងសារធាតុរ៉ែ | X= ៣៣៩៥៤៤.៧៩៩០; Y= ១៥១១២២៣.៥១៧៧<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |
| ៦ | ដែកថ្មបាយក្រៀម | ការកើតឡើងសារធាតុរ៉ែ | X=៣៣៨១៨៦.៦៣៥៣;Y= ១៥១៣៥៨៣.៧៨១៩<br>កំពស់ដាច់ខាត: >៧៥ម គ្មានជំនន់ |
| ៧ | ដែកថ្មបាយក្រៀម | ការកើតឡើងសារធាតុរ៉ែ | X= ៣២៣៣១៤.២៤០២; Y= ១៥៧៥៦១.៦៦៤៨<br>កំពស់ដាច់ខាត: < ៧៥ម ពេញជំនន់ |
| ៨ | ដែកថ្មបាយក្រៀម | ការកើតឡើងសារធាតុរ៉ែ | X= ១៣៧៥២៤.១៤៩៦; Y= ១៥០៥៧៣២.១៤៨៥<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |
| ៩ | Polymetallic sulphide | ចំនុចករកើតរ៉ែ | X= ១៣៩៦៩៨.៥៦៨៩; Y= ១៥០៥៥៣៩.៨០៤២<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |
| ១០ | ថ្មសំណង់ | ស្រទាប់រ៉ែខ្ពាតតូច | X= ១៣២៦៥៧.៣៧៨០; Y= ១៥០៣៩៩៦.២៩៦០<br>កំពស់ដាច់ខាត: <៧៥ម ជំនន់ដោយផ្នែក |
| ១១ | ថ្មសំណង់ | ស្រទាប់រ៉ែខ្ពាតតូច | X= ៣១៤០៧០.៦២៣០; Y= ១៤៩៩៥១៦.៤៦៦០<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |
| ១២ | Polymetallic gold | ការកើតឡើងសារធាតុរ៉ែ | X=១៣៦៨១៤.៦៣៩១; Y= ១៤៩៩១០៣.៩៥៣០<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |
| ១៣ | ថ្មសំណង់ | ស្រទាប់រ៉ែខ្ពាតតូច | X= ៣១៤២៥៤.២៥១០; Y= ១៤៩៦៥៦៦.៣៤៤០<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |
| ១៤ | ដែកថ្មបាយក្រៀម | ការកើតឡើងសារធាតុរ៉ែ | X= ៣២១៧១៥.៨១៨៧; Y= ១៤៩៤៤៥៦.៣៨៤៦<br>កំពស់ដាច់ខាត: <៧៥ម គ្មានជំនន់ |
| ១៥ | Facing stone | ការកើតឡើងសារធាតុរ៉ែ | X=៣២១៣៧៦.៧៣២៤; Y= ១៤៩៣៩១២.២៩៩២<br>កំពស់ដាច់ខាត: <៧៥ម គ្មានជំនន់ |
| ១៦ | ដីធ្វើអិដ្ឋ និង ក្បឿង | ស្រទាប់រ៉ែខ្ពាតតូច | X= ៣២៩៧៤៧.៥៦៤៣; Y= ១៤៨៨៦៩៦.៦៩៨០<br>កំពស់ដាច់ខាត: <៧៥ម ពេញជំនន់ |

ប្រភព: ការរុករករ៉ែ និង ការវាយតំលៃធនធានរ៉ែរបស់រោងចក្រវារីអគ្គិសនីសេសានក្រោមទី២ ខែឧសភា ២០០៨

Draft

យោងទៅតាមផែនទីភូគព្ភសាស្ត្រ និង ការរុករកធនធានរ៉ែ ស្រទាប់រ៉ែ/កន្លែងករកើតរ៉ែ លោហៈចំរុះ និង រ៉ែមាសត្រូវបានគេឃើញជាទំរង់ជាខ្សែស៊ុលហ្វីត និង សសៃក្វាតតូចៗ តំបន់បំលែងទឹកក្តៅធម្មជាតិ នៅខាងលើ សិលាគ្រឹះកើតឡើងដោយអេហ្វស៊ីវអាដ្យាសិតនៃខ្សែស៊ុលហ្វីតកំរិតទាប។ សមាសធាតុផ្សំរបស់លោហៈចំរុះ ក្រុម ទង់ដែង-សំណ-ស័ង្កសី (Cu-Pb-Zn) មានកំរិតទាប កម្រឃើញមានភ្ជាប់មកជាមួយមាស និងប្រាក់ នៅក្នុងគំរូ សំណាកណាស់។ ទំហំរបស់កន្លែងទាំងនោះមិនធំទេ។ ធនធានរ៉ែលំអិតនៅក្នុងតំបន់គំរោង (ទីតាំងអាងស្តុក) មាន ពណ៌នានៅក្នុង "របាយការណ៍សង្ខេបលើការសិក្សាការរុករក និង ការវាយតំលៃលើធនធានរ៉ែនៅអាងស្តុកទឹករោង ចក្រវារីអគ្គីសនីសេសានក្រោម ២ "។

## ៤.៣.២ ហេដ្ឋារចនាសម្ព័ន្ធ

### *៤.៣.២.១ ការផ្គត់ផ្គង់ទឹក និង អនាម័យ*

ប្រភពទឹកនៃការផ្គត់ផ្គង់ទឹកក្នុងក្រុងស្ទឹងត្រែង ត្រូវបានបូមចេញ ពីផ្នែកខ្សែទឹកក្រោមនៃតំបន់គំរោងរបស់ ទន្លេសេសាន។ បច្ចុប្បន្ននេះ ការផលិតប្រចាំថ្ងៃគឺ ១000ម៣ ក្នុងមួយថ្ងៃ ហើយផ្គត់ផ្គង់ ១៥ ម៉ោង ក្នុងមួយថ្ងៃ ប៉ុន្តែតំរូវការគឺ ២000 ម៣ ក្នុងមួយថ្ងៃ។ តំលៃទឹកគឺ ១៥00រៀលក្នុង ១ ម៣ (0.៣៧ដុល្លាក្នុង ១ ម៣) ហើយ តំបន់សេវាកម្មមានប្រហែលតែ ៤0 % ប៉ុណ្ណោះ។

គ្រួសារទាំងអស់នៅក្នុងតំបន់គំរោង ប្រើប្រាស់ទន្លេ (សេសាន និង ស្រែពក) ជាប្រភពសំរាប់ការផ្គត់ផ្គង់ទឹក ប្រចាំថ្ងៃ។ ប៉ុន្តែមានគ្រួសារមួយចំនួន ក៏បានប្រើអណ្តូងជីក និង អណ្តូងខួងផងដែរ។ យោងទៅតាមក្រុមសិក្សារបស់ KCC នៅឆ្នាំ ២00៧ បរិមាណនៃការប្រើប្រាស់ទឹកក្នុងម្នាក់ៗ គឺប្រហែល ៤៧ លីត្រក្នុងមួយថ្ងៃ ដែលរួមបញ្ចូល ទាំងការផឹក ការដាំស្ល ការបោកគក់ ការលាងសំអាត និង ការងូត។ នៅក្នុងនោះ ជាង ៩៥ %នៃទឹក ត្រូវបានដាំ មុននឹងបរិភោគ។

ការចិញ្ចឹមជ្រូក គឺជាការប្រើប្រាស់ទឹកដ៏ច្រើនមួយ (ជាពិសេស បើសិនជាមានគំរោងធ្វើការតាំងទីលំនៅសារ ជាថ្មី)។ យោងទៅតាមការសិក្សានៅទីវាល បានរកឃើញថាជាមធ្យមបរិមាណទឹក ដែលប្រើប្រាស់សំរាប់ជ្រូក មួយក្បាលក្នុងមួយថ្ងៃគឺប្រហែល ៣១ លីត្រ។ នៅក្នុងនោះ ចំនួនប្រជាជននៅក្នុងតំបន់ ៤១.៣% ចិញ្ចឹមជ្រូកពី ១-២ ក្បាល និង ២៤.១% ចិញ្ចឹមជ្រូក ៣ ក្បាល និងច្រើនជាងនេះ។ ចំនួនជ្រូកចិញ្ចឹម គឺផ្អែកទៅលើសេដ្ឋកិច្ចគ្រួសារ និង ទំនៀមទំលាប់ប្រពៃណីរបស់គេ។ សត្វស្រុកដទៃទៀតដូចជាមេគោ គោឈ្មោល និង ក្របី មិនត្រូវបានរាប់បញ្ចូល ទៅក្នុងការប្រើប្រាស់ទឹកទេ ដោយសារតែសត្វទាំងនេះ ត្រូវបានគេលែងអោយស៊ីស្មៅដោយសេរី។

ចំនួនបង្គន់នៅក្នុងឃុំនិមួយៗ មានបង្ហាញនៅក្នុងតារាង ១.១២។ ក្នុងឃុំទាំងអស់ មានតែឃុំស្រែគរមួយ ប៉ុណ្ណោះ ដែលមានបង្គន់បង្ហូរទឹកច្រើន គឺ ៣៨.៤%នៃគ្រួសារសរុប បន្ទាប់មកឃុំតាឡាត់ ៥% ក្បាលរមាស ៤.១% ស្រែអង្រ្កង 0.៦% និង ឃុំភ្លុក 0.៤% តាមលំដាប់លំដោយ។ ភាគរយនៃបង្គន់ដែលមាននៅក្នុងឃុំកាន់តែខ្ពស់ បង្ហាញពីកំរិតរស់នៅ និង ចំណេះដឹងពីការរក្សាសុខភាព កាន់តែប្រសើរជាងមុននៅក្នុងគ្រួសាររបស់ពួកគេ។ ចំពោះ



Draft

កន្លែងណាដែលគ្មានបង្គន់ ជាធម្មតាគេចោលកាកសំណល់ពីក្នុងផ្ទះនៅជុំវិញផ្ទះរបស់គេ។ គ្មានប្រព័ន្ធបង្ហូរទឹក ឬ ការគ្រប់គ្រងកាកសំណល់រឹងត្រឹមត្រូវទេ នៅក្នុងតំបន់គំរោង។ ដូច្នេះ ទឹកន្លែងអនាម័យនៅតែត្រូវបានចាត់ទុកថា ខ្វះខាត និង ចាំបាច់ត្រូវធ្វើការអភិវឌ្ឍន៍។

### ៤.៣.២.២ ប្រភពថាមពល និង ខ្សែបញ្ជូន

មានក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីខ្នាតតូចពីរ កំពុងប្រតិបត្តិការនៅក្រោមឯកជន និង រដ្ឋ(អគ្គិសនីកម្ពុជា EDC) ដោយប្រើប្រាស់ម៉ាស៊ីនភ្លើង។ ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងទីរួមខេត្តស្ទឹងត្រែង (EDC) គ្របដណ្តប់តែ ៧០% នៃតំបន់ទីរួមខេត្តប៉ុណ្ណោះ ហើយអត្រាតំលៃគឺ ១២២០រៀល/គីឡូវ៉ាត់ម៉ោង។ មានរោងចក្រវារីអគ្គិសនីពីរតូចៗ ជាមួយនឹងសមត្ថភាពផលិតពី ៥-១០គីឡូវ៉ាត់ នៅអូរពងមាន់ និង មួយទៀតនៅសៀមបូក ដែលដំណើរការដោយឯកជន។

លទ្ធផលនៃការចុះអង្កេតតាមគ្រួសារនៅក្នុងតំបន់គំរោង បានរកឃើញថា ប្រភពថាមពលដែលប្រើនៅក្នុងសហគមន៍ គឺខុសពីតំបន់ទីក្រុង។ នៅផ្នែកខាងក្រោម មានបង្ហាញយ៉ាងច្បាស់ពីប្រភពថាមពលដែលប្រើនៅក្នុងឃុំនិមួយៗ:

- នៅឃុំតាឡាត់ ប្រជាជនទាំងអស់ប្រើអុសសំរាប់ដាំស្លរ និង សំរាប់ការបំភ្លឺវិញ ប្រើចន្លុះ (ប្រហែល ៥០% នៃ គ្រួសារ) ឬ ចង្កៀងប្រេងកាត និង/ឬ ម៉ាំងសុង (ប្រហែល ៤០% នៃគ្រួសារ)។ គ្រួសារនៅសល់ (ប្រហែល ១០%) ប្រើអគ្គិសនីពីម៉ាស៊ីនភ្លើង។ នេះមានន័យថា នៅក្នុងឃុំនេះ មានតែប្រជាជននៅក្នុងភូមិខ្សាច់ថ្មីប៉ុណ្ណោះ ដែលប្រើអគ្គិសនីជាចំបងសំរាប់ការបំភ្លឺ។
- នៅឃុំស្រែគរ ប្រជាជនក៏ប្រើអុសសំរាប់ដាំស្លរ និង សំរាប់ការបំភ្លឺវិញ ប្រើចន្លុះ (ប្រហែល ១០%នៃគ្រួសារ) និង ចង្កៀងប្រេងកាត ឬ ម៉ាំងសុង (ប្រហែល ៨០%នៃគ្រួសារ) ផងដែរ។ គ្រួសារនៅសល់ (ប្រហែល ១០%) ប្រើអាគុយផ្ទាល់ខ្លួន និង ម៉ាស៊ីនភ្លើង។
- នៅឃុំភ្លុក មិនខុសពីឃុំទាំងពីរខាងលើទេ។ ប្រជាជនទាំងអស់ប្រើអុសជាធនធានសំរាប់ដាំស្លរ ខណៈដែលប្រភពសំរាប់ការបំភ្លឺ គឺប្រើចន្លុះ ១៥% ចង្កៀងប្រេងកាត និង ម៉ាំងសុង ៦៥% អាគុយ និង/ឬ ម៉ាស៊ីនផ្ទាល់ខ្លួន ប្រហែល ១០% និង អគ្គិសនីប្រហែល ១០%។
- នៅឃុំក្បាលរមាស ប្រជាជនក៏ប្រើអុស ១០០% ផងដែរជាប្រភពសំរាប់ដាំស្លរ ខណៈដែលប្រភពសំរាប់បំភ្លឺ គឺប្រើចន្លុះ ១០% ចង្កៀងប្រេងកាត និង ម៉ាំងសុង ២៥%។ អាគុយផ្ទាល់ខ្លួន និង/ឬ ម៉ាស៊ីនភ្លើងប្រហែល ១៦% និង អគ្គិសនីប្រហែល ៥០%។ ដូច្នេះគ្រួសារភាគច្រើនប្រើអគ្គិសនី។ នេះក៏ដោយសារភូមិ ៣ ក្នុងចំណោមភូមិ ៤ មានម៉ាស៊ីនភ្លើង ហើយតំលៃសំរាប់ប្រើប្រាស់អាចទទួលយកបានពីសំណាក់អ្នកស្រុក។
- នៅឃុំអ្រែង្គង ក៏ដូចជាឃុំផ្សេងទៀតនៅក្នុងតំបន់គំរោងដែរ។ ប្រជាជនក៏ប្រើអុស ១០០% ជាប្រភពសំរាប់ដាំស្លរ ខណៈដែលប្រភពសំរាប់បំភ្លឺ គឺប្រើចន្លុះ ១០% ចង្កៀងប្រេងកាត និង ម៉ាំងសុង ៦០%។ អាគុយផ្ទាល់ខ្លួន និង/ឬ ម៉ាស៊ីនភ្លើងប្រហែល ១០% និង ប្រើប្រាស់អគ្គិសនីមានប្រហែល ២០%។



Draft

## ៤.៣.៣ ការដឹកជញ្ជូន

### *៤.៣.៣.១ បណ្តាញផ្លូវ*

ផ្លូវនៅក្នុងខេត្តស្ទឹងត្រែង កំពុងត្រូវបានកែលំអពីផ្លូវដី ទៅជាគ្រួសក្រហម ផ្លូវ Makadam និង កៅស៊ូ។ ក្នុងឆ្នាំ ២០០៨ មន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្តស្ទឹងត្រែង នឹងស្ថាបនាផ្លូវ មាកាដាំ (Makadam) ៥ គម នៅក្នុងក្រុង ស្ទឹងត្រែង ។ ប៉ុន្តែនៅថ្នាក់ស្រុក បណ្តាញផ្លូវនៅមានកំរិតទាំងបរិមាណ និង គុណភាព។

ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់គំរោងកំពុងត្រូវបានកែលំអ ប៉ុន្តែបណ្តាញផ្លូវទៅភូមិខ្លះនៅតែមិនល្អ (ផ្លូវទៅស្វាយរៀង រំពាត់ និង ជាពិសេសទៅតាឡាត់)។ នេះមានន័យថា ផ្លូវនៅក្នុងភូមិខ្លះ គឺមិនអាចចូលបានទាល់តែសោះនៅក្នុងរដូវវស្សា។ ប៉ុន្តែមានផ្លូវគ្រួសក្រហម សំរាប់ធ្វើដំណើរទៅកាន់ប្រជុំជនរបស់ឃុំនិមួយៗ (រូបភាពទី ២៩)។ ដោយ សារបណ្តាញផ្លូវភ្ជាប់ពីភូមិមួយ ទៅភូមិមួយនៅខ្សត់ខ្សោយ ទន្លេសេសាន ជាញឹកញាប់ត្រូវបានគេប្រើដោយអ្នកភូមិមួយចំនួន សំរាប់ការធ្វើដំណើរ និង ដឹកជញ្ជូន។ ម៉ូតូ ត្រូវបានប្រើជាចំបងសំរាប់ការដឹកជញ្ជូនមនុស្ស និង ឥវ៉ាន់ទៅរាល់កន្លែង ដែលមានផ្លូវចូលទៅដល់ភូមិ។

Draft



a) ស្ពានកំពុងសាងសង់នៅឃុំភ្លុក



b) ផ្លូវគ្រួសក្រហមចំបងទៅកាន់ឃុំក្បាលរមាស

**រូបភាពទី ២៩:** ផ្លូវគ្រួសក្រហមចំបងទៅកាន់ប្រជុំជនឃុំនិមួយៗ

### *៤.៣.៣.២ អាកាសយានដ្ឋាន*

មានអាកាសយានដ្ឋានក្នុងស្រុកតែមួយគត់នៅក្នុងខេត្តស្ទឹងត្រែង ដែលមានទីតាំងប្រហែល ៤គម ខាងកើតទីរួមខេត្តស្ទឹងត្រែង ហើយកំពុងនៅដំណើរការ។ ប៉ុន្តែអាកាសយានដ្ឋាននេះ មិនមានសកម្មភាពទេបច្ចុប្បន្ននេះ គឺមានតែ យន្តហោះតូចៗពីរបីប៉ុណ្ណោះចុះចតក្នុងមួយខែៗ នៅពេលដែលផ្លូវជាតិដំណើរការមិនបានល្អ។ នៅពេលដែលការកសាងផ្លូវជាតិបានបញ្ចប់ កំរមានយន្តហោះចុះចតនៅក្នុងខេត្តស្ទឹងត្រែងណាស់។

### *៤.៣.៣.៣ កំពង់ផែ*

មានចំណតសាឡាងមួយនៅខាងមុខក្រុងស្ទឹងត្រែង ហើយប្រើប្រាស់សំរាប់ដឹកជញ្ជូនអ្នកដំណើរ និង យានជំនិះឆ្លងកាត់ទន្លេសេសាន ប៉ុន្តែឥឡូវនេះមិនដំណើរការទេ ដោយសារស្ពានសេកុងត្រូវបានដាក់អោយដំណើរការ កាលពីខែមេសា ២០០៨។ ក្រៅពីចំណតសាឡាងខាងលើ គ្មានផែផ្សេងទៀតទេនៅទន្លេសេសាន និង ស្រែពក លើកលែងតែទូកតូចៗ ដែលសហគមន៍ប្រើសំរាប់ឆ្លងពីភូមិមួយទៅភូមិមួយ។

### ៤.៣.៣.៤ នាវាចរណ៍

ផ្អែកលើពតិមានដែលបានទទួលពីមន្ទីរសាធារណការ និង ដឹកជញ្ជូន ( PDPWT )ខេត្តស្ទឹងត្រែង លោក សាន នូ ជានាយករង បានបង្ហាញថា បើអាចធ្វើទៅបានគេគួរសាងសង់សន្ទះផ្លូវទឹកមួយ ដើម្បីឆ្លងកាត់ទៅខ្សែទឹកលើ និង ខ្សែទឹកក្រោមនៃទំនប់។ ប៉ុន្តែសព្វថ្ងៃនេះ ទូកដឹកទំនិញចំណុះ១.៥-៣តោនមានពីរ បីប៉ុណ្ណោះដែលធ្វើដំណើរតាមទន្លេសេសាន ។ រៀងរាល់ថ្ងៃ ពួកគេឈប់ធ្វើដំណើរតាមផ្លូវទឹក ចាប់តាំងពីផ្លូវជាតិលេខ ៧៨ ត្រូវបានកែលំអមក. បើតាមប្រសាសន៍លោកជំទប់ឃុំភ្លុក។

ក្រុមសិក្សាបានធ្វើការរាប់ចរាចរណ៍ទូកនៅស្ថានីយ៍បីខុសៗគ្នា:

(១) ស្ថានីយ៍ទន្លេសេសានខ្សែទឹកក្រោមនៃទំនប់

(២) ស្ថានីយ៍ទន្លេសេសានខ្សែទឹកលើនៃទំនប់

(៣) ស្ថានីយ៍ទន្លេស្រែពកខ្សែទឹកលើនៃទំនប់

តារាងទី ៣៤ បង្ហាញពីលទ្ធផលនៃការរាប់ចរាចរណ៍ពីថ្ងៃទី ៣១ មករា ដល់ថ្ងៃទី ១៥ កុម្ភៈ ២០០៨។ ក្រាដាសលំអិតនៃការរាប់ចរាចរណ៍មានផ្តល់អោយនៅក្នុងឧបសម្ព័ន្ធទី ២។

**តារាងទី ៣៤:** ការរាប់ចរាចរណ៍ (ទូក)

| ថ្ងៃទី | ស្ថានីយ៍ភ្លុក (១) | | ស្ថានីយ៍ស្រែគរ (២) | | ស្ថានីយ៍ក្បាលរមាស (១) | |
|---|---|---|---|---|---|---|
| | លើ | ក្រោម | | | | |
| ៣១-មករា | ៥៤ | ២៥ | ២៣ | ១៨ | ៧ | ៦ |
| ១-កុម្ភៈ | ៥៤ | ២៦ | ២០ | ២០ | ៦ | ៦ |
| ២- កុម្ភៈ | ៥១ | ៣៧ | ១៧ | ១៣ | ៥ | ៨ |
| ៣- កុម្ភៈ | ៤៨ | ៣៦ | ១៤ | ១២ | ៨ | ៨ |
| ៤- កុម្ភៈ | ៨៤ | ៥៦ | ១៨ | ១៥ | ៧ | ៦ |
| ៥- កុម្ភៈ | ៨០ | ៥៦ | ២០ | ១៨ | ៦ | ៦ |
| ៦- កុម្ភៈ | ៩៤ | ៤៦ | | | | |
| ៧- កុម្ភៈ | ១០២ | ៥២ | | | | |
| ៨- កុម្ភៈ | ៩១ | ៩០ | | | | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| ៩- កុម្ភៈ | ៩០ | ៨៨ | | | | |
| ១០- កុម្ភៈ | ៨៥ | ៨៣ | | | | |
| ១១- កុម្ភៈ | ៧១ | ៨៧ | | | | |
| ១២- កុម្ភៈ | ៨៥ | ១០១ | | | | |
| ១៣- កុម្ភៈ | ៩២ | ៨៦ | | | | |
| ១៤- កុម្ភៈ | ៨៧ | ៨៥ | | | | |
| ១៥- កុម្ភៈ | ៧៥ | ៨០ | | | | |
| សរុប | ១២៤៣ | ១០៣៤ | ១១២ | ៩៦ | ៣៩ | ៤០ |
| មធ្យម | ៧៨ | ៦៥ | ១៩ | ១៦ | ៧ | ៧ |

**ចំណាំ:** ការរាប់ចរាចរណ៍ធ្វើឡើងនៅពេលថ្ងៃតែប៉ុណ្ណោះ (៦:០០ព្រឹក ដល់ ៦:០០ល្ងាច)

ក្រុមសិក្សាបានរកឃើញថា ចរាចរណ៍ទូកភាគច្រើនទាំងនៅទន្លេសេសាន និង ស្រែពក ត្រូវបានប្រើសំរាប់ដឹកជញ្ជូនគ្រួសារជាមួយនឹងការផ្ទុកធម្មតាតិចជាង ១តោន និង ធ្វើដំណើរពីភូមិមួយទៅមួយ។ ប៉ុន្តែទូកដឹកទំនិញតិចតួចដែលមានចំណុះអតិបរមា ១.៥តោន នៅតែធ្វើនាវាចរណ៍នៅក្នុងទន្លេទាំងពីរ ដែលមានតែនៅរដូវប្រាំងប៉ុណ្ណោះ យោងទៅតាមសំដីលោកមេឃុំ។ ក្នុងតារាងទី ២ បង្ហាញពីសកម្មភាពនាវាចរណ៍ទាំងខ្សែទឹកក្រោម និង ខ្សែទឹកលើនៃទំនប់ដែលស្នើសុំដូចខាងក្រោម:

- ស្ថានីយ៍ភ្លុក (១) ៧ គម ខាងក្រោមខ្សែទឹកនៃទីតាំងទំនប់ទន្លេសេសាន: ប្រជាជនភាគច្រើននៅទីនេះប្រើកាណូតតូចៗ។ មានទូកពី ៦៥-៧៨ កំពុងដំណើរការ សំរាប់ការដឹកជញ្ជូនមនុស្ស និង ទំនិញប្រចាំថ្ងៃពីភូមិមួយទៅភូមិមួយ និង ទៅទីរួមខេត្តស្ទឹងត្រែង។ នៅក្នុងរូបភាពខាងលើ មានទូកពី ១០-១៥ កំពុងធ្វើដំណើរឆ្លងកាត់ទៅភូមិនៅខ្សែទឹកលើរបស់ទំនប់ យោងទៅតាមជំទប់ឃុំភ្លុក។
- ស្ថានីយ៍ស្រែគរ (២) ២៣ គម ខាងលើខ្សែទឹកនៃទីតាំងទំនប់ទន្លេសេសាន: មានកាណូតតូចៗមួយចំនួន (១៦-១៩ ទូក) កំពុងដំណើរការនៅឃុំស្រែគរសំរាប់ការដឹកជញ្ជូនប្រចាំថ្ងៃ ទាំងមនុស្ស និង ទំនិញពីភូមិមួយទៅភូមិមួយ។
- ស្ថានីយ៍ក្បាលរមាស (៣) ៣៥ គម ខាងលើខ្សែទឹកនៃទីតាំងទំនប់របស់ទន្លេសេសាន: មានកាណូតតូចៗតិចតួចប៉ុណ្ណោះ (៧ទូក) កំពុងដំណើរការនៅឃុំក្បាលរមាស។

### ៤.៣.៤ ការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅស្រុកសេសាន គឺសំបូរទៅដោយព្រៃឈើ ដែលមាននឹងផ្ទៃក្រឡាសរុប ២៤៤.៣៨០ ហត ឬ ៩០.៤% នៃផ្ទៃដីសរុបរបស់ស្រុក ខណៈដែលដីកសិកម្មមាន ៦.០២១ហត ឬ ២.២%ប៉ុណ្ណោះ ហើយដីសំរាប់



Draft

ប្រើប្រាស់ផ្សេងទៀតមានទំហំតូច សូមមើលប្រភេទនៃការប្រើប្រាស់ដីក្បោះកាយនៅក្នុងតារាងទី ៣៥ និង រូបភាពទី ៣០ ។

**តារាងទី ៣៥:** ប្រភេទនៃការប្រើប្រាស់ដីនៅស្រុកសេសាន។

| ប្រភេទដីប្រើប្រាស់ | ទំហំ (ហត) | ភាគរយ (%) |
|---|---|---|
| ដីកសិកម្ម | ៦.០២១ | ២,២ |
| គ្របដណ្តប់ដោយព្រៃ | ២៤៤.៣៨០ | ៩០.៤ |
| វាលស្មៅ | ៣.៩១១ | ១.៤ |
| ព្រៃល្បោះ | ៨.២៦៩ | ៣.១ |
| ដី និង ថ្ម | ២២២ | ០,១ |
| ទឹកដែលមានស្រាប់ | ៧.៥៣៣ | ២.៨ |
| **សរុប** | **២៧០.៣៣៧** | **១០០,០** |

ប្រភព : JICA ២០០៣, ផ្អែកលើ landsat (TM) ឆ្នាំ ២០០០

អាស្រ័យតាមការគ្រោងរបស់គំរោងរោងចក្រវារីអគ្គីសនីសេសានក្រោម ២ ដីសំរាប់ប្រើប្រាស់នៅក្នុងឃុំទាំងបី ស្រែគរ តាឡាត់ និង ក្បាលរមាស នឹងត្រូវលិចកប់ក្នុងអាងស្តុកទឹក។ តំបន់ជន់លិចលំអិតពីប្រភេទដីប្រើប្រាស់និមួយៗមានបង្ហាញក្នុងតារាងទី៣៦ ។រូបភាពទី៣០បង្ហាញពីតំបន់ដីប្រើប្រាស់ដែលជន់លិច និងខូចខាតដោយគំរោង។

**តារាងទី ៣៦:** ដីសំរាប់ប្រើប្រាស់នឹងជន់លិចនៅក្នុងអាងស្តុកទឹកជាមួយ FSL ៧៥ម

| កំរិតទឹក ៧៥ម | |
|---|---|
| **ប្រភេទដីសំរាប់ប្រើប្រាស់** | **ផ្ទៃក្រឡា (ហត)** |
| គ្របដណ្តប់ដោយព្រៃ | ២៨.៩៦៩.៤៩៥ |
| ទឹកដែលមានស្រាប់ | ២.៩៨៩.៦៥៣ |
| ដីកសិកម្ម | ១.២៩០.៥៥៨ |
| វាលស្មៅ | ២១៨.៧១៤ |
| ដី និង ថ្ម | ៤៨.១០៩ |
| ព្រៃរបោះ | ៤៧.៣៩២ |
| **សរុប** | **៣៣.៥៦៣.៩២១** |

Draft

Draft




| LandUse Type | Area (ha) |
|---|---|
| Agricultural lands | 6,021 |
| Forest covers | 244,380 |
| Grasslands | 3,911 |
| Shrublands | 8,269 |
| Soils and Rocks | 222 |
| Water Features | 7,533 |
| Total | **270,337** |

**រូបភាពទី ៣០៖ ផែនទីដីប្រើប្រាស់របស់ស្រុកសេសាន**

ដីស្រែក្នុងគ្រួសារនិមួយៗនៅក្នុងតំបន់គំរោង ប្រែប្រួលពីឃុំមួយទៅឃុំមួយ។ តាមការសិក្សាស្រាវជ្រាវនៅទីកន្លែងផ្ទាល់ គេបានរកឃើញថាដីស្រែដែលកាន់កាប់ប្រែប្រួលពី ០.៥ហត ទៅ ១២ហត។ គ្រួសារដែលបានសំភាសន៍ទាំងអស់ បានរាយការណ៍ថាពួកគេមានដីកាន់កាប់ផ្ទាល់ខ្លួន ដែលមិនមែនជាកម្មសិទ្ធិរបស់ឪពុកម្តាយ ឬ ជួលពីអ្នកដទៃឡើយ។ តារាងទី ៣៧ បង្ហាញពីរបាយដីស្រែកម្មសិទ្ធិរបស់គ្រួសារ តាមទំហំខុសៗគ្នា។ សរុបទាំងអស់នៅក្នុងតំបន់គំរោង ២.៨ ភាគរយកាន់កាប់ដី ០.៥ហត ឬ តិចជាងនេះ ២១ ភាគរយ កាន់កាប់ដីច្រើនជាង ០.៥ហត ទៅតិចជាង ២ហត, ៥៩.១ ភាគរយ កាន់កាប់ដីពី ២ហត ទៅ ៤ហត និង ១៧.១ ភាគរយ កាន់កាប់ដីច្រើនជាង ៤ ហត។ សំអាងទៅលើម្ចាស់កម្មសិទ្ធិ ផ្អែកទៅតាមការសិក្សានៅទីវាល ម្ចាស់កម្មសិទ្ធិដីភាគច្រើនដែលកាន់កាប់ ពុំមានលិខិតកាន់កាប់ដីធ្លីទេ។ ប៉ុន្តែ ពួកគេត្រូវបានទទួលស្គាល់ដោយត្រឹមត្រូវពីអជ្ញាធរក្នុងតំបន់នៅកំរិតភូមិ ឃុំ និង ស្រុក។

**តារាងទី ៣៧:** ការកាន់កាប់ ដីស្រែ

| តំបន់គំរោង | >0-0.៥ ហត | >0.៥- <២ ហត | ២-៤ ហត | >៤ ហត | សរុប |
|---|---|---|---|---|---|
| ចំនួនគ្រួសារ (HH) | ៥ | ៣៨ | ១០៧ | ៣១ | ១៨១ |
| ភាគរយ (%) | ២.៨ | ២១ | ៥៩.១ | ១៧.១ | ១០០ |

តារាងទី ៣៨ បង្ហាញពីរបាយគ្រួសារដែលជាម្ចាស់កម្មសិទ្ធិដីដាំដំណាំដែលមានទំហំខុសៗគ្នា។ ជាលទ្ធផលពីការសំភាសន៍របស់ក្រុមសិក្សា មានគ្រួសារ ១៧.៣ ភាគរយ កាន់កាប់ដី ០.៥ហត ឬ តិចជាងនេះ ៤៤ ភាគរយ កាន់កាប់ដីច្រើន ជាង ០.៥ ហត ទៅតិចជាង ២ហត ៣៤.២ ភាគរយ កាន់កាប់ដី ២ហត និង ៤ហត និង ៧.៧ ភាគរយ មានច្រើនជាង ៤ហត។ ៧៤ គ្រួសារ ទៀតមិនមានដីទេ។ ស្រដៀងទៅនឹងដីស្រែដែរ ស្ទើរតែទាំងអស់នៃដីដាំដំណាំពុំមានលិខិតបញ្ជាក់ពីកម្មសិទ្ធិទេ។ សំអាងទៅលើម្ចាស់កម្មសិទ្ធិ ផ្អែកទៅតាមការសិក្សានៅទីវាល ម្ចាស់កម្មសិទ្ធិដីភាគច្រើនដែលកាន់កាប់ដី ពុំមានលិខិតកាន់កាប់ដីធ្លីទេ។ ប៉ុន្តែដីប្រភេទនេះក៏ត្រូវបានទទួលស្គាល់ដោយត្រឹមត្រូវ ដោយអជ្ញាធរក្នុងតំបន់នៅ កំរិតភូមិ ឃុំ និង ស្រុកផងដែរ។

**តារាងទី ៣៨:** ដីដាំដំណាំដែលបានកាន់កាប់

| តំបន់គំរោង | >0-0.៥ហត | >0.៥-<២ហត | ២-៤ហត | >៤ហត | សរុប |
|---|---|---|---|---|---|
| ចំនួនគ្រួសារ (HH) | ១៦ | ៥២ | ៤០ | ៩ | ១១៧ |
| ភាគរយ (%) | ១៣.៦៨ | ៤៤.៤៤ | ៣៤.១៩ | ៧.៦៩ | ១០០ |

### ៤.៣.៥ ការអភិវឌ្ឍន៍កសិកម្ម

ដីកសិកម្មសរុបនៅស្រុកសេសានគឺ ៥២២០ហត ដែលនៅក្នុងនោះ ៤៩៥០ហត ជាស្រែវស្សា និង ២៧០ហត ជាដីកសិកម្មខ្ពង់រាប។ សេសាន គឺជាជង្រុកស្រូវចំបងមួយនៃខេត្តស្ទឹងត្រែង បើតាមទិន្នន័យដែលទទួលបានពីប្រធានមន្ទីរកសិកម្មខេត្ត។ ដីកសិកម្មតំបន់ខ្ពង់រាបមាន (i) ការអនុវត្តការដាំដុះចល័តៈ ស្រូវចំការ ពោត ដំឡូងមី ចេក ។ល។ និង (ii) ការអនុវត្តន៍ការដាំដុះនៅមួយកន្លែងៈ ស្វាយ ម្នាស់ ស្វាយចន្ទី ចេក ។ល។



Draft

យោងទៅតាមការសិក្សានៅទីកន្លែងជាក់ស្តែងបានរកឃើញថា នៅតាមដងទន្លេសេសាន និង ស្រែពក ប្រជាជនចូលចិត្តធ្វើស្រែ ដែលគេស្គាល់ថាជាស្រូវចំការ និងផលិតកម្មដំណាំសំរាប់មួយរដូវក្នុងមួយឆ្នាំ។ ដូច្នេះគ្មានស្រូវ និង/ឬ ផលិតកម្មដំណាំណាមួយ ត្រូវបានធ្វើទៅនៅក្នុងរដូវប្រាំងទេ។ នេះមិនមែនមានន័យថា គ្មានធារាសាស្ត្រនៅក្នុងរដូវប្រាំងទេ ប៉ុន្តែជាការខ្វះនូវមធ្យោបាយដើម្បីស្រោចស្រពដីរបស់គេ ឬប្រហែលជាមកពីប្រពៃណីរបស់គេដែលទំលាប់ដាំតែមួយរដូវ។ ការដាំស្រូវចំការ ជាទូទៅត្រូវបានបែងចែកជាពីរប្រភេទៈ កសិកម្ម ពនេចរ និង អចិន្ត្រៃយ៍។ កសិកម្មពនេចរ ទាក់ទងទៅនឹងការសំអាតព្រៃដើម្បីដាំស្រូវ និង ដំណាំដទៃទៀតសំរាប់រយៈពេលពី ២-៥ ឆ្នាំ មុននឹងធ្វើការផ្លាស់ទី/វិលទៅកន្លែងមួយទៀត។ ក្នុងករណីភាគច្រើន កសិករធ្វើការសំអាតតំបន់ដែលបានដាំដុះពីមុន ហើយបានទុកទំនេរចោលជាច្រើនឆ្នាំ។ កសិកម្មអចិន្ត្រៃយ៍មានដូចជា ការដាំស្រូវនៅកន្លែងដដែលៗរាល់ឆ្នាំ ជាពិសេសក្បាលដីតូចៗដែលនៅជិតផ្ទះកសិករ (McKenney B. and Prom T. 2003)។ ចាប់តាំងពីកសិកម្មពនេចរ មិនមានអនុវត្តបន្តទៀតនោះ ការអនុវត្តន៍ជាចំបងក្នុងពេលបច្ចុប្បន្ន គឺកសិកម្មអចិន្ត្រៃយ៍។

ស្រូវចំការដែលប្រើប្រាស់ទឹកភ្លៀង ត្រូវបានចាត់ទុកថាជាដំណាំមានច្រើនជាងគេ ដោយចាប់ផ្តើមស្ទូងនៅខែមិថុនា និង ច្រូតកាត់ខែ តុលា ទៅ ធ្នូ។ រយៈពេច្រូតកាត់គឺអាស្រ័យទៅលើប្រភេទស្រូវ។ ឧទាហរណ៍ ស្រូវស្រាលជាធម្មតាត្រូវបានប្រមូលផលបន្ទាប់ពីដាំបានរយៈពេល ៣ខែ ខណៈដែលស្រូវធ្ងន់តែងតែត្រូវបានប្រមូលផល បន្ទាប់ពីដាំបានរយៈពេល ៦ខែ។ ដំណាំបន្ទាប់បន្សំ ត្រូវបានដាំនៅក្នុងទំរង់ជាចំការចំរុះ។ ដំណាំប្រភេទនេះ ត្រូវបានដាំដោយគ្មានការស្រោចស្រព។ នេះមានន័យថា ទោះបីជាវាលស្រែនៅក្បែរទន្លេ សេសាន និង ស្រែពកក៏ដោយ ក៏ពួកគេពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀងដែរ។ យោងទៅតាមការពឹងផ្អែកលើទឹកភ្លៀង ស្រូវចំការគេស្ទូងនៅរដូវវស្សា ហើយច្រូតនៅចុងរដូវវស្សា ឬ នៅពេលឈប់ភ្លៀង អាស្រ័យទៅតាមពូជស្រូវ និង កត្តាផ្សេងទៀតដូចជារបបទឹកភ្លៀង លក្ខខណ្ឌអាកាសធាតុ។ នៅតាមវាលស្រែតំបន់ខ្ពង់រាប ភាគច្រើនដំណាំចំរុះ គឺស្រូវ និង ដំណាំមួយចំនួនទៀតដូចជា ពោត ដំឡូងជ្វា ដំឡូងមី សណ្តែកបាយ ល្ពៅ បន្លែ និង ដំណាំដទៃៗទៀត។

**តារាងទី ៣៩:** ទិន្នផលស្រូវតាមឃុំ

| ឃុំ | ទិន្នផលស្រូវរដូវវស្សា (តោន/ហត) |
|---|---|
| តាឡាត់ | ២.០ |
| ស្រែគរ | ១.៥ |
| ភ្លុក | ១.៨ |
| ក្បាលរមាស | ១.៥ |
| ស្រែអង្រ្កង | ១.០ |

ប្រភព: ឯកសារឃុំ, ២០០៧

ទិន្នផលស្រូវប្រែប្រួលពីឃុំមួយទៅមួយ ដូចបានបង្ហាញនៅក្នុងតារាងទី ៣៩ អាស្រ័យទៅលើពូជស្រូវ ការអនុវត្តន៏កសិកម្ម ប្រភេទដី និង កត្តាផ្សេងៗទៀត។ នៅឃុំណាដែលមានទិន្នផលស្រូវខ្ពស់ បង្ហាញថាឃុំនោះមានដីល្អសំរាប់ស្រូវ។ តាមបែបកសិកម្ម ដីខ្មៅមានជីជាតិជាងដីក្រហម ដែលមានទីតាំងនៅឆ្ងាយពីស្ទឹងបន្តិច ដែលទំនងជាភាគច្រើនធ្លាប់បានគ្របដណ្តប់ដោយព្រៃឈើ គឺជាដីមានលក្ខណៈល្អប្រសើរសំរាប់ធ្វើស្រែ និងចំការផ្លែឈើ។ អ្នកភូមិ នៅតាមដងស្ទឹង ភាគច្រើនបានរាយការណ៍ថា ដីស្រែរបស់គេ អាចផ្តល់អោយគេនូវអាហារគ្រប់គ្រាន់ជាច្រើនឆ្នាំមកហើយ។ ការអង្កេតជាក់ស្តែង បានរកឃើញនូវគំរូទូទៅមួយ និង របាយដំណាំចំរុះ តាមរយៈទេសភាពដែលមានទំនាក់ទំនងជាមួយទន្លេសេសាន។

ចំការផ្លែឈើមានចំងាយឆ្ងាយពីទន្លេ ហើយវាមានលក្ខណៈធម្មតា សំរាប់អ្នកភូមិ ដែលរស់នៅក្បែរទន្លេសេសាន និង ស្រែពក ដោយវាបានផ្តល់នូវប្រភពចំណូលបន្ថែម ខណៈដែលសួនដំណាំនៅក្បែរផ្ទះ និង ស្ថិតនៅចន្លោះផ្ទះ និង ទន្លេ (SWECO 2006)។ ដំណាំទាំងនោះត្រូវបានបែងចែកជាបីចំណាត់ថ្នាក់ៈ ដំណាំដាំនៅសួនក្បែរផ្ទះ, ដំណាំ/រុក្ខជាតិផ្តល់អាហារ ស្ថិតនៅខាងក្រោយផ្ទះ (ទីធ្លាខាងក្រោយ) និង រុក្ខជាតិដែលប្រើសំរាប់ដាំ នៅក្បែរមាត់ស្ទឹង និង/ឬ តាមជំរាលច្រាំងដងទន្លេ (តារាងទី ៤០)។

**តារាងទី ៤០ៈ** បញ្ជីដំណាំ និង ឈើហូបផ្លែនៅក្នុងតំបន់គំរោង

| រុក្ខជាតិដែលដាំនៅសួនក្បែរផ្ទះ | | ដំណាំ និង ឈើហូបផ្លែស្ថិតនៅខាងក្រោយផ្ទះ (ទីធ្លាក្រោយផ្ទះ) | | រុក្ខជាតិដែលប្រើសំរាប់ដាំនៅក្បែរមាត់ស្ទឹង និង/ឬ តាមជំរាលច្រាំងតាមមាត់ទន្លេ | |
|---|---|---|---|---|---|
| ឈ្មោះក្នុងតំបន់ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះក្នុងតំបន់ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះក្នុងតំបន់ | ឈ្មោះភាសាអង់គ្លេស |
| អំពិល | Tamarind | អំពិល | Tamarind | អំពៅ | Sugar cane |
| ចេក | Banana | អំពៅ | Sugar cane | ខ្ទឹមស | Spring onion |
| ជីរ អង្កង | Mint | ចេក | Banana | ល្មុត | Species of Sapotaceae |
| ជីរ ក្រហម | Basil | ជីរអង្កង | Mint | ល្ង | Sesame |
| ជីរវ៉ាន់ស៊ុយ | Coriander | ដំឡូងជ្វា | Sweet potatoes | ល្ពៅ | Pumpkin |
| ដើម ដូង | Coconut tree | ដំឡូងគរ | Cassava | ម្នាស់ | Pineapple |
| ដើម គរ | Bombax | ដើម ដូង | Coconut tree | ម្ទេស | Chili |
| ដើម ទឹកដោះគោ | Milk fruit | ដើម គ | Bombax | ឪឡឹក | Water melon |
| ខ្នុរ | Jackfruit | ដើមទឹកដោះគោ | Milk fruit | ពោត | Corn |
| ខ្ទឹម | Spring onion | ខ្ញី | Ginger | ស្លា | Betel nut |

| | | | | | |
|---|---|---|---|---|---|
| ក្រូចឆ្មារ | Lemon (lime) | ខ្នុរ | Jackfruit | ស្ពៃ | Lettuce |
| ក្រូចពោធិសាត់ | Orange | ក្រូចពោធិសាត់ | Orange | ស្វាយ | Mango |
| ក្រូចថ្លុង | Pomelo | ល្ហុង | Papaya | ស្វាយចន្ទី | Cashew |
| ល្ហុង | Papaya | ល្មុត | Species of Sapotaceae | ថ្នាំជក់ | Tobacco |
| ល្មុត | Species of Sapotaceae | ល្ងរ | Sesame | ត្រប់ក្លិប | Aubergine |
| មៀន | Longan | មៀន | Longan | ត្រកួន | Morning glory |
| ម្លូរ | Peper betel | សណ្តែកបាយ | Mung bean | ត្រាវ | Taro |
| ម្ទេស | Chili | សេដា | Pomelo | | |
| ននោង | Long gourd -2 (smooth surface) | ស្លឹកគ្រៃ | Lemon grass | | |
| រំចេក | Pandan | ស្ពឺ | Corambole | | |
| រំដេង | Galanga | ស្ពៃ | Lettuce | | |
| សណ្តែកគួរ | Long bean | ស្វាយ | Mango | | |
| ស្លា | Betel nut | ស្វាយចន្ទី | Cashew | | |
| ស្លឹកគ្រៃ | Lemon grass | ថ្នាំជក់ | Tobacco | | |
| ស្ពឺ | Corambole | ត្រាវ | Taro | | |
| ស្ពៃ | Lettuce | | | | |
| ស្វាយ | Mango | | | | |
| ស្វាយចន្ទី | Cashew | | | | |
| ត្រប់ | Species of Solaneaceae | | | | |
| ត្របែក | Guava | | | | |
| ត្រប់ក្តរគោ | Aubergine | | | | |
| ត្រឡាច | Long gourd - 1 (hairy) | | | | |
| ត្រសក់ | Cucumber | | | | |

Draft

សំគាល់: ដំណាំ និង ឈើហូបផ្លែទាំងនេះ រាយការណ៍ដោយអ្នកភូមិ កត់ត្រាក្នុងពេលសិក្សានៅទីវាល ហើយចងក្រងនៅទីនេះ តាមលំដាប់អក្ខរក្រមឈ្មោះក្នុងតំបន់ ។ ប៉ុន្តែ ដំណាំខ្លះពិបាកនៅក្នុងការកំណត់ឈ្មោះរបស់វាដោយសារគេហៅវាជា ភាសាឡាវ ។

អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការខាងផ្នែកកសិកម្មនៅក្នុស្រុកសេសានមានដូចជា:

- សកម្មភាពដៃគូរអភិវឌ្ឍន៍ (DPA) (Development Partner in Action)
- សហគមន៍ព្រៃឈើ
- សហគមន៍ជលផល
- PFD (គំរោងចប់នៅពាក់កណ្តាលឆ្នាំ ២០០៧)
- VSO (ផ្តោតទៅលើសុខភាព)
- CEPA

### ៤.៣.៦ វិស័យទេសចរណ៍

មានធនធានធម្មជាតិ និង ធនធានសង្គមមួយចំនួន បំរើអោយការអភិវឌ្ឍន៍ទេសចរណ៍ ក្នុងខេត្តស្ទឹងត្រែង។ វាសំបូរទៅដោយព្រៃឈើជាច្រើនប្រភេទនៅក្នុងទឹកដីខេត្តទាំងមូល និង ជំរកសត្វព្រៃខ្លះៗ រួមបញ្ចូលទាំងសត្វទឹក និង គោក (ផ្សោតនៅទន្លេមេគង្គ ស្ថានីយ៍រាមស ក្នុងខេត្តស្ទឹងត្រែង)។ ប្រាសាទ និង វត្តចាស់ៗ មានវត្តមាននៅក្នុងស្រុកមួយចំនួន ឧទាហរណ៍ប្រាសាទព្រះគោនៅក្នុងស្រុកថាឡាបរិវ៉ាត់។

ទាក់ទងទៅនឹងតំបន់គំរោង ប្រាសាទមួយឈ្មោះ ភូ ស្ថិតនៅក្នុងភូមិកំភុន ឃុំភ្លុក ស្រុកសេសាន ដែលស្ថិតនៅខ្សែទឹកក្រោមនៃទំនប់ដែលបានស្នើសុំ សំរាប់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោម ២។

មានទឹកធ្លាក់តូចៗ ជាច្រើននៅក្នុងទន្លេសេសាន និង ស្រែពក ហើយខ្លះបានផ្តល់ជាសក្តានុពលសំរាប់ការអភិវឌ្ឍន៍ទេសចរណ៍ ជាពិសេសទឹកធ្លាក់នៅក្នុងភូមិភ្លុក និង ទឹកជ្រោះ អូរចាប់ ក្នុងភូមិកំភុន ឃុំភ្លុក ស្រុកសេសាន ស្ថិតនៅខ្សែទឹកក្រោម ខាងក្រោយរោងចក្រវារីអគ្គិសនីសេសានក្រោម ២។ បច្ចុប្បន្នទឹកធ្លាក់ទាំងពីរនៅឃុំភ្លុក បានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីទេសចរណ៍ជាតិ។

ថ្មីៗនេះអាស្រ័យដោយមានសន្តិសុខ ១០០% និង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនត្រូវបានកែលំអរួចរាល់ និង ភាពសំបូរទៅដោយធនធានធម្មជាតិ ជាពិសេស ព្រៃឈើ និង ត្រី ជាហេតុធ្វើអោយខេត្តស្ទឹងត្រែងបានទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិយ៉ាងច្រើនអោយមកលេង និង ទស្សនា។ គេអាចនិយាយបានទៀតផងដែរថា ខេត្តស្ទឹងត្រែង គឺជាកន្លែងមានសក្តានុពលមួយសំរាប់ទេសចរណ៍ធម្មជាតិ។

Draft

## ៤.៤ ធនធានសង្គម និង វប្បធម៌

### ៤.៤.១ ប្រជាជន

តាមវិស័យរដ្ឋបាល ខេត្តស្ទឹងត្រែងមានស្រុកចំនួន ៥ ដែលមាន ៣៤ឃុំ និង ១២៨ភូមិ។ យោងទៅតាមទិន្នន័យដែលមាននៅក្នុងខេត្ត នៅចុងឆ្នាំ ២០០៧-២០០៨ ខេត្តនឹងមានប្រជាជនសរុប ៩៨៣៧៤ នាក់ (តារាងទី ៤១)។ ដង់ស៊ីតេប្រជាជននឹងមាន ៨.១៩នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។

**តារាងទី ៤១: ស្ថិតិប្រជាជននៅក្នុងខេត្តស្ទឹងត្រែង ឆ្នាំ ២០០៧**

| លរ | ពណិនា | ស្រុក | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ស្ទឹងត្រែង | សេសាន | សៀម បុក | តាឡាត់ | សៀមប៉ាង | |
| ១ | ចំនួនឃុំ | ៤ | ៧ | ៧ | ១១ | ៥ | ៣៤ |
| ២ | ចំនួនភូមិ | ១៧ | ២២ | ១៧ | ៤៤ | ២៨ | ១២៨ |
| ៣ | ចំនួនគ្រួសារ | ៥៥២៤ | ២៧១៦ | ៣២២០ | ៤៦៥០ | ៣០៩៦ | ១៩២០៦ |
| ៤ | ប្រជាជនសរុប | ២៧២២០ | ១២៩៦១ | ១៨៣៥៨ | ២៥០៨០ | ១៤៧៥៥ | ៩៨៣៧៤ |

ប្រភព: សៀវភៅស្ថិតិប្រចាំឆ្នាំរបស់ខេត្តស្ទឹងត្រែង ឆ្នាំ ២០០៧-២០០៨

តំបន់គំរោង មានទីតាំងនៅក្នុងស្រុកសេសាន។ ស្រុកនេះ មានព្រំដែនភូមិសាស្ត្រជាមួយស្រុកសៀមប៉ាងនៅផ្នែកខាងជើង ខេត្តមណ្ឌលគីរី នៅខាងត្បូង ស្រុកស្ទឹងត្រែងនៅខាងលិច និង ខេត្តរតនគីរី នៅខាងកើត។ ប្រជាជននៅក្នុងតំបន់គំរោងមានពណិនានៅក្នុងតារាងទី ៤២។

**តារាងទី ៤២: ចំនួនប្រជាជនក្នុងតំបន់គំរោងនៅឆ្នាំ ២០០៧**

| ឃុំ | ឈ្មោះភូមិ | # គ្រួសារ | ប្រជាជន | ស្ត្រី | ទំហំគ្រួសារ |
|---|---|---|---|---|---|
| តាឡាត់ | តាឡាត់ | ៧២ | ៣៥៩ | ១៨០ | ៥.០ |
| | រំពាត់ | ៥៣ | ២២១ | ១១១ | ៤.២ |
| | ស្វាយរៀង | ២៥៦ | ១១៧២ | ៦០១ | ៤.៦ |
| | ខ្សាច់ថ្មី | ២៥៥ | ១១៦៣ | ៥៨៥ | ៤.៦ |
| ស្រែគរ | ស្រែគរមួយ | ១៦៥ | ៧៤៩ | ៣៧៦ | ៤.៥ |
| | ស្រែគរពីរ | ១៥៨ | ៧២៨ | ៣៧២ | ៤.៦ |
| ភ្លុក | ភ្លុក | ១៩៦ | ៨០៣ | ៤០២ | ៤.១ |
| | បានប៊ុង | ៦៨ | ២៨៩ | ១៤៧ | ៤.៣ |
| ក្បាលរមាស | ក្របីជ្រុំ | ១៧៧ | ៧៩៨ | ៤០៧ | ៤.៥ |
| | ក្បាលរមាស | ១០៦ | ៥៣៨ | ២៦៥ | ៥.១ |
| | ស្រែស្រណុក | ១០៤ | ៥២៩ | ២៤៥ | ៥.១ |
| | ស្រែពក | ៤៧ | ១៩៥ | ៩៧ | ៤.១ |
| | សរុប | ***១៦៥៧*** | ***៧៥៤៤*** | ***៣៧៨៨*** | |

ប្រភព: ឯកសារឃុំ, ២០០៧

Draft

## ជនជាតិភាគតិច និង សាសនា

ផ្នែកនេះផ្តល់ពត៌មានពីសាសនា និង ជាតិជាតិភាគតិច ដែលបានយកមកពីឯកសារឃុំ និង ការអង្កេតគ្រួសារ ដោយក្រុមសិក្សាតាមលំដាប់លំដោយ។ ទោះបីជាមានក្រុមជនជាតិភាគតិចខុសៗគ្នាច្រើន រស់នៅក្នុងភូមិតាមដង ទន្លេសេសាន និង ស្រែពក (SWECO ២០០៦ សិក្សានៅតាមទន្លេសេសាន និង ស្រែពក និង បណ្តាញការពារទន្លេ 3S ២០០៧) ក៏ដោយ ក៏មានគ្រួសារតិចតួចប៉ុណ្ណោះ ដែលឃើញរស់នៅក្នុងតំបន់គំរោង។ ក្រុមជនជាតិដែលរស់នៅក្នុងតំបន់គំរោងមានដូចជា ចារ៉ាយ ឡាវ គ្រឹង ភ្នង និង ព្រៅ។ រូបភាពទី ៣១ បង្ហាញពីភាគរយនៃក្រុមជនជាតិភាគតិចដែលបានសំភាសន៍នៅក្នុងតំបន់គំរោង។ ទោះជាយ៉ាងណាក៏ដោយ នៅខ្សែទឹកលើ និង ក្រោមនៃតំបន់គំរោង ក៏មានចំនួនក្រុមជនជាតិភាគតិចយ៉ាងច្រើន ជាពិសេស ឡាវ និង ភ្នង។




**រូបភាពទី ៣១:** ជនជាតិភាគតិចនៅក្នុងតំបន់គំរោង

Draft

ទោះបីជាជនជាតិភាគតិចខ្លះដូចជា ចារ៉ាយ ឡាវ គ្រឹង ភ្នង និង ព្រៅ ត្រូវបានរាយការណ៍ដោយបណ្តាញការពារទន្លេ 3S ឆ្នាំ ២០០៧ នៅក្នុងតំបន់គំរោង ក៏ជនជាតិខ្លះយើងមិនបានជួប និង ធ្វើសំភាសន៍ក្នុងពេលធ្វើការសិក្សានៅទីវាលឡើយ ដោយសារពួកគេជាប់រវល់។ ដូច្នេះ អ្នកដែលត្រូវបានសំភាសន៍មានតែជនជាតិខ្មែរ ឡាវ និង ភ្នង ប៉ុណ្ណោះ។ ភាគរយខ្ពស់ជាងគេនៅក្នុងតំបន់គំរោងគឺជនជាតិខ្មែរ ដែលមានប្រហែល ៦០% នៃអ្នកដែលបានសំភាសន៍ បន្ទាប់មកដោយជនជាតិឡាវដែលស្ទើតែទាំងអស់រស់នៅក្នុងស្រុកស្រែគរ (មានប្រហែល ៣៣%) និង ភ្នងភាគច្រើនរស់នៅក្នុងភូមិក្បាលរមាស (មានប្រហែល ៧%)។

### ៤.៤.២ វិស័យសុខភាព

នៅក្នុងឃុំតាឡាត់ គ្មានមណ្ឌលសុខភាពទេ។ បើសិនជាមានអ្នកជំងឺនៅក្នុងឃុំ ពួកគេត្រូវធ្វើដំណើរឆ្ងាយទៅរកមណ្ឌលសុខភាពនៅខេត្តស្ទឹងត្រែង។ ជាមធ្យម ចំងាយពីឃុំតាឡាត់ទៅមណ្ឌលសុខភាពគឺប្រហែល១២៨គម (ឯកសារឃុំតាឡាត់ ឆ្នាំ ២០០៧)។ នេះបញ្ជាក់ថាបច្ចុប្បន្ននេះ គ្មានមធ្យោបាយសុខភាពត្រូវបានផ្តល់អោយសំរាប់ឃុំនេះទេ។ នៅឃុំស្រែគរ ក៏គ្មានមណ្ឌលសុខភាពដែរ។ ជាមធ្យម ចំងាយពីឃុំស្រែគរទៅការិយាល័យសុខភាពខេត្តគឺប្រហែល ៩០គម (ឯកសារ ឃុំស្រែគរឆ្នាំ ២០០៧)។ នៅឃុំភ្លុក គ្មានមណ្ឌលសុខភាពឃុំទេ កន្លែងដែលនៅជិតបំផុត គឺមណ្ឌលសុខភាពឃុំកំភុន។ ជាមធ្យម ចំងាយពីឃុំភ្លុកទៅមណ្ឌលសុខភាពឃុំកំភុនគឺប្រហែល ៨.៥ គម (ឯកសារឃុំភ្លុក ឆ្នាំ ២០០៧)។ វាមានភាពងាយស្រួលណាស់ សំរាប់ប្រជាជននៅក្នុងឃុំភ្លុក ដើម្បីទទួលបានសេវា

សុខភាព។ ចំងាយពីឃុំក្បាលរមាស ទៅមណ្ឌលសុខភាពដែលនៅជិតបំផុតគឺប្រហែល ៤០គម (មណ្ឌលសុខភាពកូនមុំ ខេត្តរតនគិរី)។



**រូបភាពទី ៣២:** មណ្ឌលសុខភាពនៅស្រុកកូនមុំ ខេត្តរតនគិរី

គ្រប់ឃុំទាំងអស់ នៅក្នុងតំបន់គំរោងមានចំនួនតិចណាស់ ដែលបំរើសេវាសុខភាព។ ជាញឹកញាប់ប្រជាជនខ្លះប្រើរុក្ខជាតិថ្នាំនៅក្នុងតំបន់ សំរាប់ការព្យាបាលរបស់ពួកគេ។ ក្នុងពេលខ្លះ ការសំរាលបុត្ររបស់ស្ត្រីភាគច្រើនគឺអាស្រ័យទៅលើឆ្មបបុរាណ។ ដោយសារគ្មានមណ្ឌលសុខភាពឃុំនៅក្នុងតំបន់គំរោង អ្នកផ្តល់ពតិមានគន្លឹះជាច្រើនដូចជា មេភូមិ អនុមេភូមិ និង ព្រឹទ្ធាចារ្យនៅក្នុងភូមិ ត្រូវបានសួរពីរឿងរ៉ាវសុខភាព។ ជាលទ្ធផល គេបានរកឃើញថាជំងឺដែលទាក់ទងទៅនឹងទឹក និង មូសមានច្រើន។ ជំងឺដែលទាក់ទងទៅនឹងទឹកមានដូចជា ជំងឺរាគធម្មតា រាគធ្ងន់ធ្ងរ រាគមូល ជំងឺឆ្លងស្បែក ជាដើម។ល។ ខណៈដែលជំងឺទាក់ទងទៅនឹងសត្វមូសមានដូចជា គ្រុនចាញ់ និង ជំងឺភ្នែក។ ជំងឺទាំងនេះត្រូវបានរាយការណ៍ថាកើតឡើងនៅក្នុងគ្រួសារភាគច្រើន ពេញមួយឆ្នាំ។

**តារាងទី ៤៣:** ជំងឺសំខាន់ៗដែលបានកត់ត្រានៅក្នុងតំបន់គំរោង

| លរ | ជំងឺ | មណ្ឌលសុខភាព | |
|---|---|---|---|
| | | កំពុន | កូនមុំ |
| ១ | រាគធម្មតា | ៨០ | ២៤៩ |
| ២ | រាគធ្ងន់ធ្ងរ | ០ | ០ |
| ៣ | គ្រុនចាញ់ | ៧៨ | ១០ |
| ៤ | គ្រុនឈាម | ០ | ០ |
| ៥ | ជំងឺឆ្លងស្បែក | ១០២ | ១៥ |
| ៦ | ជំងឺភ្នែក | ៤៣ | ២១ |

ប្រភព: មណ្ឌលសុខភាព, ២០០៧

Draft

ទិន្នន័យសុខភាពដែលមានត្រូវបានទទួលពីឃុំកំពុន និង ឃុំស្រែអង្រ្កង ដែលទិន្នន័យពីជំងឺ ត្រូវបានកត់ត្រាដូចមានបង្ហាញនៅក្នុងតារាងទី ១.១១។ ប៉ុន្តែនៅឃុំកំពុន ទិន្នន័យទៅលើជំងឺចំបង១ មិនអាចតំណាងអោយលក្ខខណ្ឌសុខភាពនៅក្នុងឃុំភ្លុកទេ ប៉ុន្តែវាអាចផ្តល់ជាប្រវត្តិសំរាប់ស្ថានភាពជំងឺទូទៅ។ ដូច្នេះ ជំងឺចំបង១នៅក្នុងឃុំភ្លុក គឺទាបជាងអ្វីដែលមានបង្ហាញនៅក្នុងតារាង ១.១៣ ពីព្រោះតារាងបង្ហាញពីទិន្នន័យនៅក្នុងឃុំទាំងពីរ គឺភ្លុក និង កំពុន។ ជំងឺ ដែលសំបូរច្រើនជាងគេនៅក្នុងឃុំភ្លុក គឺជំងឺឆ្លងសើរស្បែក បន្ទាប់មកគឺ ជំងឺរាគធម្មតា គ្រុនចាញ់ និង ជំងឺភ្នែក។ ជំងឺភ្នែក ជំងឺឆ្លងសើរស្បែក និង គ្រុនចាញ់ក៏មិនសូវមាននៅក្នុងឃុំដែរ។ ជំងឺរាគធម្មតា ជាទូទៅត្រូវបានសន្មត់ថា បណ្តាលមកពីកង្វះអនាម័យ និង ប្រភពទឹកស្អាត។

ផ្អែកទៅតាមទិន្នន័យដែលទទួលបានពីការអង្កេតនៅទីវាលបានរកឃើញថា ជំងឺដែលសំបូរជាងគេគឺជំងឺរាគមូល បន្ទាប់មកគឺជំងឺសើរស្បែក ជំងឺគ្រុនពោះវៀន គ្រុនចាញ់ និង អាសន្នរោគ។ ជាមូលដ្ឋាន ការឆ្លងនៃជំងឺរាគមូលគឺបានឆ្លងតាមរយៈអនាម័យមិនបានត្រឹមត្រូវ។ មូលហេតុមួយ ក្នុងចំណោមមូលហេតុជាច្រើននៃជំងឺរាគមូល គឺការមិនលាងសំអាតដៃបន្ទាប់ពីបន្ទោរបង់នៅក្នុងបង្គន់ ឬ នៅជុំវិញដុំព្រៃ ដែលនៅមិនឆ្ងាយពីផ្ទះ។ ជំងឺស្បែកក៏មានកំរិតខ្ពស់ដែរ នៅក្នុងកំឡុងពេលសិក្សា។ វាហាក់ដូចជាមានការពិបាក ដើម្បីធ្វើការសំរេចពីមូលហេតុនៃជំងឺបែបនេះ មិនដឹងថាមកពីការប្រើប្រាស់ទឹករាល់ថ្ងៃ ឬអ្វីផ្សេងទៀត ប៉ុន្តែមូលហេតុមួយដែលទំនងជាងគេ គឺកង្វះអនាម័យ។ ជំងឺផ្សេងទៀត សំបូរកើតឡើងនៅគ្រប់ទីកន្លែងនៅពាសពេញប្រទេស។

### ៤.៤.៣ វិស័យអប់រំ

វិស័យអប់រំគឺកំពុងត្រូវបានកែលំអ ដែលបណ្តាលអោយមានការលូតលាស់យឺត១។ កំរិតនៃការសិក្សា និង អត្រាអនក្ខរភាព នៅក្នុងចំណោមស្ត្រី ជាទូទៅមានទាបជាងបុរស។ មានភាពខុសគ្នាផងដែរចំពោះទីក្រុង និង ជនបទ ដែលបានរកឃើញពីភាពខុសគ្នាយ៉ាងច្បាស់ (CIPS ២០០៤)។ ដោយសារវិស័យអប់រំជាផ្នែកមួយយ៉ាងសំខាន់ វាមានការចាំបាច់ណាស់ដើម្បីធ្វើអោយវាលេចឡើង ចេញពីតំបន់គំរោង។

ប៉ុន្តែមុននឹងពណ៌នាអំពីអត្រានៃអនក្ខរភាព គេគួរតែផ្តោតការយកចិត្តទុកដាក់ទៅលើសេវាសាលារៀន។ តាមការសិក្សា មិនមានវិទ្យាល័យ ត្រូវបានរកឃើញនៅក្នុងតំបន់គំរោងឡើយ ។ ប៉ុន្តែមានអនុវិទ្យាល័យ ២ នៅក្នុងឃុំស្រែអង្រ្កង និង ឃុំស្រែគរ។ នៅឃុំស្រែគរ អនុវិទ្យាល័យស្ថិតនៅជិតភូមិ នឹងត្រូវរងផលប៉ះពាល់ដោយគំរោង បើសិនជាគេសាងសង់។ ម៉្យាងទៀត នៅឃុំស្រែអង្រ្កង ចំងាយពីភូមិទៅអនុវិទ្យាល័យត្រពាំងក្រហម មានប្រហែល ២២ គម។ សាលានេះ ហាក់ដូចជានឹងមិនរងផលប៉ះពាល់ដោយសារគំរោងទេ ប៉ុន្តែវាត្រូវបានបញ្ចូកនៅទីនេះ ដើម្បីអោយដឹងអំពីសេវាអប់រំនៅក្នុងតំបន់គំរោង។ នៅក្នុងឃុំទាំងអស់ សុទ្ធតែមានសាលាបឋមសិក្សា (តារាង ទី ៤៤)។ ចំនួនសាលាបឋមសិក្សា គឺអាស្រ័យទៅលើទីតាំងរបស់ភូមិទាំងនោះ។ ជាក់ស្តែង នៅឃុំក្បាលរមាស ដោយសារចំងាយពីភូមិមួយទៅមួយឆ្ងាយ សាលាបឋមសិក្សាត្រូវបានសាងសង់បន្តបន្ទាប់គ្នានៅក្នុងភូមិទាំងអស់ដើម្បីជួយសំរួលដល់សេវាអប់រំនៅក្នុងឃុំ។



Draft

តារាងទី ៤៤: ចំនួនសាលា និង គ្រូ

| ឃុំ | បឋមសិក្សា | # ថ្នាក់ | អនុវិទ្យាល័យ | # ថ្នាក់ |
|---|---|---|---|---|
| តាឡាត់ | ៤ | ២១ | 0 | 0 |
| ស្រែគរ | ១ | ៧ | ១ | ៥ |
| ភ្លុក | ២ | ១២ | 0 | 0 |
| ក្បាលរមាស | ៤ | ៣២ | 0 | 0 |
| ស្រែអង្គ្រង | ១ | ៤ | 0 | 0 |

ប្រភព: មន្ទីរអប់រំខេត្តស្ទឹងត្រែង, ២០០៧




Draft

**រូបភាពទី ៣៣: អត្រាអនក្ខរភាពយោងទៅតាមភេទ និង ឃុំ**

រូបភាពទី ៣៣ បង្ហាញពត៌មានអំពីអនក្ខរភាព និង កំរិតសិក្សាអាស្រ័យតាមភេទ។ អត្រាអនក្ខរភាពត្រូវបានគណនាពីប្រជាជនបុរស និង ស្ត្រីដែលមានអាយុពី ១៥-៦០ ឆ្នាំ នៅក្នុងភូមិនិមួយៗតាមលំដាប់លំដោយ។ ប៉ុន្តែភាគរយរបស់អនក្ខរជនជាស្ត្រី មានខ្ពស់ជាងបុរសនៅក្នុងឃុំទាំងបី: ភ្លុក, តាឡាត់ និង ក្បាលរមាស។ ភាគរយទាំងបុរស និង ស្ត្រីមានស្រដៀងគ្នាចំពោះស្រុកស្រែគរ ដោយសារប្រជាជននៅក្នុងភូមិនេះ ភាគច្រើនជាជនជាតិឡាវ ដែលជាលទ្ធផលធ្វើអោយអត្រាអនក្ខរភាពមិនមានការខុសគ្នាខ្លាំងរវាងបុរស និង ស្ត្រី។ ប៉ុន្តែវាខុសគ្នានៅក្នុងឃុំស្រែអង្គ្រង ដែលអនក្ខរជនជាបុរសមានខ្ពស់ជាងស្ត្រី។ ជាមូលដ្ឋាននៅក្នុងប្រទេស កំរិតនៃការអប់រំ និង អត្រាអនក្ខរភាពក្នុងចំណោមស្ត្រីនៅក្នុងប្រទេសទាំងមូល មានអត្រាខ្ពស់ជាងបុរស។ ភាគរយជាមធ្យមនៃអត្រាអនក្ខរភាព នៅក្នុងឃុំទាំងអស់ មានពន្យល់នៅក្នុងរូបភាពទី ៣៤។




**រូបភាពទី ៣៤: ភាគរយនៃអនក្ខរជននៅក្នុងតំបន់គំរោង**

ទោះបីជាមានសាលបឋមសិក្សាច្រើននៅក្នុងតំបន់គំរោងក៏ដោយ ចំនួនសិស្សដែលបានបន្តការសិក្សារបស់ពួកគេនៅអនុវិទ្យាល័យ និង ខ្ពស់ជាងនេះ មានចំនួនតិចតួច។ ជាទូទៅ គេបោះបង់ការសិក្សា នៅពេលគេបញ្ចប់ថ្នាក់ទី ១-៥ ឬ នៅបឋមសិក្សា។ ជាលទ្ធផល ភាគរយនៃអនក្ខរជនមានអត្រាខ្ពស់។ រូបភាពទី ៣៤ បង្ហាញពីភាគរយមធ្យមនៃអត្រាអនក្ខរជនរបស់បុរស និង ស្ត្រីនៅក្នុងឃុំនិមួយៗ។ នៅឃុំស្រែអង្រ្កង ភាគរយមានតិច ៧.៥ % បើប្រៀបធៀបទៅឃុំដទៃទៀត។ ម៉្យាងទៀត ដោយសារឃុំស្ថិតនៅជិតអនុវិទ្យាល័យត្រពាំងក្រហម ក្នុងទីរួមស្រុកកូនមុំ. កន្លែងដែលមានចំងាយប្រហែល ២២ គម ពីឃុំ។ ម៉្យាងទៀត វាអាចបង្ហាញថា ឪពុកម្តាយបានអោយតំលៃទៅលើការសិក្សារបស់កូនតាំងពីដំបូង ដើម្បីអាចអោយកូនសិក្សាបន្ថែមបន្ត។ បន្ថែមលើនេះ បន្ទាប់ពីបញ្ចប់បឋមសិក្សា សិស្សស្រី/ប្រុស អាចបន្តការសិក្សានៅកំរិតអនុវិទ្យាល័យ។ នៅឃុំភ្លុក ភាគរយជាមធ្យមគឺ ១២.៦%។ នេះប្រហែលដោយសារឃុំនេះស្ថិតនៅជិតទីរួមខេត្ត កន្លែងដែលមានសាលារៀនច្រើន។ ដូច្នេះសេវាអប់រំអាចមានភាពប្រសើរជាងឃុំដទៃនៅក្នុងតំបន់គំរោង ជាហេតុអត្រាអ្នកចេះអក្សរមានខ្ពស់។ នៅឃុំក្បាលរមាស ភាគរយនៃអនក្ខរភាពគឺ ១៥.៨ % ខ្ពស់ជាងឃុំ ២ ទៀតដែលបានរៀបរាប់ខាងលើ។ នេះក៏ដោយសារសេវាកម្មសិក្សាថ្នាក់មូលដ្ឋាន មានទាបជាងនៅឃុំ ២ ទៀតនោះ ហើយមូលហេតុដទៃទៀតគឺប្រហែល ដោយសារឪពុកម្តាយ មិនសូវបានយកចិត្តទុកដាក់ទៅលើការសិក្សារបស់កូន និង ភាពក្រីក្រ។ គ្រួសារខ្លះនៅក្នុងឃុំ គឺជាក្រុមជនជាតិភាគតិចដូចជាភ្នង ព្រៅ គ្រឹង ខារិត និង ទំពួន តាមលំដាប់លំដោយ។ នេះអាចចូលរួមធ្វើអោយមាន អនក្ខរភាពខ្ពស់នៅក្នុងឃុំផងដែរ។ នៅឃុំតាឡាត់ ភាគរយនៃអនក្ខរភាពក៏មានកំរិតខ្ពស់ដែរគឺ ១៦.៣%។ នេះ គឺដោយសារឃុំនេះ មានតែបឋមសិក្សា។ ទិដ្ឋភាពចំបងមួយក្នុងចំណោមនោះ គឺឪពុកម្តាយមិនបានផ្តល់តំលៃ និង ខ្វល់ខ្វាយពីការសិក្សារបស់កូន។ ការបង្រៀនមិនទៀងទាត់ និង កង្វះគ្រូក៏ជាឬសគល់សំខាន់នៃអត្រាអនក្ខរភាពខ្ពស់ផងដែរ។ នៅឃុំស្រែគរ ភាគរយនៃអនក្ខរភាពគឺ ១៨% ខ្ពស់ជាងឃុំដទៃនៅក្នុងតំបន់គំរោង។ នេះគឺដោយសារ គ្រួសារស្ទើរតែទាំងអស់ជាជនជាតិឡាវ ហើយពួកគេមិនចូលចិត្តរៀនភាសាខ្មែរ។ ម៉្យាងទៀត កំរិតនៃការសិក្សារបស់អ្នកផ្តល់ចំលើយ គឺដូចមានបញ្ជាក់នៅក្នុងរូបភាពទី ៣៥ ។

Draft




**រូបភាពទី ៣៥: ភាគរយនៃកំរិតសិក្សារបស់អ្នកផ្តល់ចំលើយ**

រូបភាពទី ១.៧ បង្ហាញថាអ្នកផ្តល់ចំលើយតិចតួច ដែលភាគច្រើនជាមេគ្រួសារ សិក្សាត្រឹមតែអនុវិទ្យាល័យ ឬ ខ្ពស់ជាងនេះ។ ប៉ុន្តែភាគរយនៃកំរិតសិក្សារបស់គេ មានខ្ពស់ត្រឹមបឋមសិក្សា។ ទោះបីជាដូច្នេះក៏ដោយ អ្នកផ្តល់ចំលើយភាគច្រើនធ្លាប់សិក្សាត្រឹមថ្នាក់ទី ១-២។ នេះបង្ហាញថា ទោះបីជាគេធ្លាប់សិក្សានៅកំរិតនោះក៏ដោយ ក៏ពួកគេមិនអាចអាន ឬ សរសេរបានល្អដែរ។ ដូច្នេះ គឺវាស្មើទៅនឹងអ្នកផ្តល់ចំលើយមិនបានសិក្សាដូច្នេះដែរ។

កំរិតអនក្ខរភាពខ្ពស់ អាចត្រូវបានពន្យល់ដោយមូលហេតុច្រើនយ៉ាង។ មូលហេតុសំខាន់បំផុតមួយក្នុងចំណោមនោះគឺប្រពៃណី។ គេអាចសន្និដ្ឋានបានថា ករណីភាគច្រើនគឺឪពុកម្តាយមិនផ្តល់តំលៃ និង/ឬ ខ្វាយខ្វល់អំពីការសិក្សារបស់កូនទេ ហើយមូលហេតុដទៃទៀតមានដូចជាភាពក្រីក្រ ការបង្រៀនមិនទៀងទាត់ ដោយសារខ្វះគ្រូ និង ផ្លូវឆ្ងាយទៅកាន់អនុវិទ្យាល័យ និង វិទ្យាល័យ។ ភាពក្រីក្រ ត្រូវបានចាត់ទុកជាមូលហេតុឫសគល់មួយ។ នេះ គឺដោយសារក្មេងៗទាំងនោះ តែងតែជាប់រវល់ជាមួយកិច្ចការខ្លះៗ ទោះបីជាគេកំពុងសិក្សាក៏ដោយ គឺដើម្បីផ្គត់ផ្គង់ការងារគ្រួសារ និង/ឬ ដើម្បីរកកំរៃក្រៅដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ដូច្នេះ វាបានចូលរួមយ៉ាងគួរអោយកត់សំគាល់ទៅដល់កំរិតអប់រំទាបនៅក្នុងតំបន់គំរោង។

Draft

**៤.៤.៤ លក្ខខណ្ឌសង្គមសេដ្ឋកិច្ច**

មុននឹងស្វែងយល់អំពីលក្ខខណ្ឌសេដ្ឋកិច្ចសង្គម ជាចាំបាច់ណាស់ដែលត្រូវស្គាល់អំពីការប្រកបរបរចិញ្ចឹមជីវិតជាមុនសិន។ ការប្រកបរបរចិញ្ចឹមជីវិត ត្រូវបានគេអោយនិយមន័យថា ជាការចូលរួមនៃសមត្ថភាព ទ្រព្យសម្បត្តិរួមបញ្ចូលទាំងសំភារៈ និង ធនធានសង្គម និងសកម្មភាព ដែលត្រូវការសំរាប់ជាមធ្យោបាយសំរាប់រស់នៅ (DFID,១៩៩៩)។ ការប្រកបរបរចិញ្ចឹមជីវិត មួយអាចស្ថិតស្ថេរទៅបាននៅពេលណាវាអាចយកឈ្នះ និង ងើបចេញពីភាពស្មុគស្មាញ និង ភាពតក់ស្លុតទាំងឡាយ ហើយអាចរក្សាឬជំរុញ សមត្ថភាពរបស់វា និង ទ្រព្យសម្បត្តិរបស់វាទាំងបច្ចុប្បន្ន និង ទៅអនាគត ដោយមិនធ្វើអោយអន្តរាយដល់ធនធានធម្មជាតិ (DFID,១៩៩៩)។ នានាភាពនៃជីវភាពត្រូវបានចាត់ទុកជាផ្លូវមួយ ដែលបុគ្គលនិមួយៗ និង គ្រួសារផ្លាស់ប្តូរនូវមធ្យោបាយរបស់គេក្នុងការរកចំណូល និង ការរស់នៅ (IMM, CFDO និង CBNRM LI. ២០០៥)។

នៅប្រទេសកម្ពុជា នានាភាពនៃជីវភាព គឺជាផ្នែកសំខាន់បំផុត និង ជាចំណែកមួយនៃជីវិតនៅក្នុងតំបន់

ជនបទ។ វាមិនគ្រាន់តែផ្តល់ការរកកំរៃដើម្បីផ្គត់ផ្គង់ចំណូលចំបងរបស់គ្រួសារដែលជាញឹកញាប់មិនគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែក៏បានកាត់បន្ថយគ្រោះថ្នាក់ដែលកើតឡើងពីការពឹងពាក់ទៅលើតែប្រភពសន្សំតែមួយគត់ (Ellis ២០០០)។ ប្រជាជននៅក្នុងតំបន់គំរោងខ្សែទឹកលើ និង ក្រោមនៃតំបន់គំរោង ទោះជាយ៉ាងណាក៏គ្មានភាពខុសគ្នាពីតំបន់ជនបទដទៃទៀតនៅក្នុងប្រទេសឡើយ។ មានន័យថា ជាព្រៃពៃណី ពួកគេបានផ្សារភ្ជាប់ទៅនឹងកសិកម្ម អាស្រ័យទៅតាមសកម្មភាពមួយចំនួនដើម្បីធានាពីសុវត្ថិភាពស្បៀង និង ចំណូល ដែលមានដូចជាស្រូវ ដំណាំចំការដទៃទៀត សួនក្បែរផ្ទះ និង ផលិតកម្មបសុសត្វ ការនេសាទ ការប្រមូលផលិតផលព្រៃឈើ ប្រាក់កំរៃពលកម្ម និង អ្នកជំនួញខ្នាតតូច និងដទៃទៀត។ តារាងទី ៤៥ បង្ហាញថាមុខរបរចំបងនៅក្នុងតំបន់គំរោងគឺ ៨៨ ភាគរយ ជាកសិករ ហើយផ្សេងទៀតរួមបញ្ចូលទាំង អ្នករាជការ កម្មករជាដើម។ មុខរបរបន្ទាប់បន្សំ គឺភាគច្រើនជាអ្នកនេសាទ។

**តារាងទី ៤៥:** មុខរបរចំបងរបស់ប្រជាជន និង ចំណូលប្រចាំខែ

| មុខរបរចំបង | *ភាគរយ* | *ចំណូលប្រចាំខែ* | |
|---|---|---|---|
| | % | *រៀល* | *ដុល្លា* |
| កម្មករនៅតាមក្រុមហ៊ុន/រោងចក្រឯកជន | ០.៥ | *១៣៥៨០០* | *៣៣.៩៥* |
| អ្នករាជការ | ១១.០ | *៨៤១០០* | *២១.០៣* |
| ម្ចាស់ហាងតូច | ០.៥ | *១៣១២០០* | *៣២.៨១* |
| កសិករ | ៨៨.០ | *១៣៣៩០០* | *៣៣.៤៨* |
| សរុប | ១០០ | | |

*អត្រាប្តូរប្រាក់នៅខែមិថុនា ២០០៨, US$ ១ = ៤០០០ រៀល*

**តារាងទី ៤៦:** មុខរបរបន្ទាប់បន្សំរបស់ប្រជាជន

| មុខរបរបន្ទាប់បន្សំ | *ភាគរយ* | *ចំណូលប្រចាំខែ* | |
|---|---|---|---|
| | % | *រៀល* | *ដុល្លា* |
| អ្នកជំនួញខ្នាតតូច/ជំនួញ | ១៦.៣ | *១៩៣០០០* | *៤៨.២៥* |
| អ្នកនេសាទ | ៤១.៩ | *១៥០៨០០* | *៣៧.៧០* |
| អ្នករត់ម៉ូតូឌុប សេវាកម្មដឹកជញ្ជូន | ៥.២ | *៨៣៣០០* | *២០.៨៣* |
| អនុផលព្រៃឈើ ការកាប់ឈើ | ១៣.៦ | *២៩០៥០០* | *៧២.៦៣* |
| ផ្សេងៗ | ២៣.០ | *៨៧៥០០* | *២.៨៨* |
| សរុប | ១០០ | | |

*អត្រាប្តូរប្រាក់នៅខែមិថុនា ២០០៨, US$ ១ = ៤០០០ រៀល*

Draft

ក្រៅពីធ្វើការដាំដុះយ៉ាងទៀងទាត់នូវដំណាំស្រូវ និង ដំណាំផ្សេងៗ និង ការចិញ្ចឹមសត្វ អ្នកភូមិពឹងផ្អែកលើ (i) ប្រាក់ខែ ឬ ប្រាក់ឈ្នួលពីការងាររដ្ឋាភិបាល/ក្រៅរដ្ឋាភិបាល (ii) ការនេសាទ (iii) ការងារប្រើកំលាំង (iv) ចំណូលពីលក់សត្វចិញ្ចឹម (v) ចំណូលពីការលក់ស្រូវ និង/ឬ គ្រាប់ធញ្ញជាតិ (vi) អនុផលព្រៃឈើដូចជាការប្រមូលជ័រ និង ធនធានព្រៃឈើផ្សេងៗ (NTFP) (vii) អ្នកផ្តល់សេវាដឹកជញ្ជូន ដោយទូក គោយន្ត និង ក្នុងករណីខ្លះដោយរថយន្ត និង (viii) ចំណូលបន្ថែមពីមធ្យោបាយដទៃទៀតដូចជា ជួលទ្រព្យសម្បត្តិអោយគេជាដើម។ ចំណូលសរុបសំរាប់កំឡុងពេលពេញមួយឆ្នាំ ត្រូវបានគណនាពីប្រភពនិមួយៗដូចមានអោយនិយមន័យនៅខាងលើ ហើយបូករួមបញ្ចូលគ្នា។ អ្នកផ្តល់សំភាសន៍ ត្រូវបានសួរដើម្បីរំលឹកពីចំណូលរបស់ពួកគេពីប្រភពដែលអាចមានក្នុងកំឡុងពេល ១២ ខែកន្លងទៅជាមួយនឹងចំណុចយោង ដែលបានបញ្ជាក់យ៉ាងច្បាស់ចាប់ពីខែមករា ដល់ខែធ្នូ ២០០៧ ។

Draft